# គណិតវិទ្យា




## ១១

ភាគ១

រៀបរៀងដោយ សុខ ពិសិដ្ឋ

ស្របតាមកម្មវិធីសិក្សាថ្មី

រក្សាសិទ្ធិ

# អារម្ភកថា

សួស្តីលោកគ្រូ អ្នកគ្រូ ប្អូនៗសិស្សានុសិស្ស និងប្រិយមិត្តអ្នកអានទាំងអស់ជាទីមេត្រី !

សៀវភៅ **គណិតវិទ្យាថ្នាក់ទី១១ ភាគ១** ដែលលោកគ្រូ អ្នកគ្រូ ប្អូនៗសិស្សានុសិស្ស និង ប្រិយមិត្តកំពុងអាននេះ ខ្ញុំបាទរៀបចំឡើងក្នុងគោលបំណង ជួយសម្រួលក្នុងការបង្រៀនសម្រាប់លោកគ្រូ អ្នកគ្រូ ដែលមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំមេរៀនដើម្បីបង្រៀនសិស្ស និងសម្រាប់ ប្អូនៗសិស្សានុសិស្សដែលស្វ័យសិក្សាស្រាវជ្រាវ។ ក្នុងសៀវភៅនេះ ខ្ញុំបានរៀបចំយ៉ាងលំអិតនូវមេរៀននីមួយ រួមមាន ៖

- ☞ គន្លឹះដោះស្រាយ
- ☞ លំហាត់គំរូ
- ☞ លំហាត់អនុវត្តន៍ និង លំហាត់ជ្រើសរើសផ្សេងៗ

ខ្ញុំបាទសូមអភ័យទោស នូវរាល់កំហុសទាំងឡាយដែលកើតឡើងដោយអចេតនាក្តី ដោយការពិនិត្យមិនបានសព្វគ្រប់ជ្រុងជ្រោយក្តី ឬ ដោយបច្ចេកទេសកុំព្យូទ័រក្តី ខ្ញុំបាទរង់ចាំទទួលនូវមតិរិះគន់បែបស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូ ប្អូនៗសិស្សានុសិស្ស និងប្រិយមិត្តអ្នកអានទាំងអស់ដោយក្តីសោមនស្សរីករាយ។

សូមជូនពរ លោកគ្រូ អ្នកគ្រូ ប្អូនៗសិស្សានុសិស្ស និងប្រិយមិត្តអ្នកអានទទួលបានជោគជ័យគ្រប់ភារកិច្ច និង ការសិក្សា។

កំពង់ត្របែក ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣

អ្នករៀបរៀង


សុខ ពិសិដ្ឋ

លេខទូរស័ព្ទ : **016 510 532**

**088 80 60 387**

E-mail : pisethsok87@yahoo.com

# មាតិការ

**មេរៀនទី១ ស្វ៊ីតនៃចំនួនពិត** ........ ១
១. និយមន័យ ........ ១
២. តួទី $n$ នៃស្វ៊ីត ........ ៧
៣. អថេរភាពស្វ៊ីត ........ ១០
៣.១. ស្វ៊ីតកើន ស្វ៊ីតចុះ ........ ១០
៣.២. ស្វ៊ីតម៉ូណូតូន ........ ១៦
៤. ស្វ៊ីតទាល់ ........ ២០
៤.១ ស្វ៊ីតទាល់លើ ........ ២០
៤.២. ស្វ៊ីតទាល់ក្រោម ........ ២១
៤.៣. ស្វ៊ីតទាល់ ........ ២២
**មេរៀនទី២ ស្វ៊ីតនព្វន្ត** ........ ២៩
១. និយមន័យ ........ ២៩
២. តួទី $n$ នៃស្វ៊ីតនព្វន្ត ........ ២៩
៣. ផលបូកតួនៃស្វ៊ីតនព្វន្ត ........ ៣៨
**មេរៀនទី៣ ស្វ៊ីតធរណីមាត្រ** ........ ៥៣
១. និយមន័យ ........ ៥៣
២. តួទី $n$ នៃស្វ៊ីតធរណីមាត្រ ........ ៥៤
៣. ផលគុណតួស្មើចម្ងាយពីតួចុង ........ ៦១
៤. ផលបូកតួនៃស្វ៊ីតធរណិមាត្រ ........ ៦៦
៥. ស្វ៊ីតធរណីមាត្រអនន្តតួ ........ ៧៥
**មេរៀនទី៤ ផលបូកតួនៃស្វ៊ីតផ្សេងៗ** ........ ៨៥
១. របៀបគណនាផលបូក ........ ៨៥
២. គណនាផលបូកតាមគំរូ ........ ៩២
៣. និមិត្តសញ្ញា $\Sigma$ សម្រាប់ផលបូកតួនៃស្វ៊ីត ........ ៩៣
៣.១. សញ្ញាណ $\Sigma$ ........ ៩៣
៣.២. លក្ខនៈនៃ $\Sigma$ ........ ៩៤
៤. របៀបកំណត់តួទី $n$ តាមផលសងតួនៃស្វ៊ីត ........ ៩៧

៤.១ ផលសងតួលំដាប់ទី១........................................................ ៩៧
៤.២ ផលសងតួលំដាប់ទី២......................................................១០១
**មេរៀនទី៥ ទំនាក់ទំនងតួនៃស៊ីត**......................................................១០៩
១. កំណត់តួទី $n$ ដោយប្រើស៊ីតជំនួយ .............................................១០៩
២. ទំនាក់ទំនងរវាង $a_n$ និង $S_n$ ..................................................១១៨
៣. របៀបកំណត់តួទី $n$ នៃស៊ីតដែលកំណត់ដោយ $a_1 = \alpha$ , $a_2 = \beta$
និង $a_{n+2} + pa_{n+1} + qa_n = 0$ ............................................. ១១៩

# មេរៀនទី ១ ស្វ៊ីតនៃចំនួនពិត

## ១. និយមន័យ

> ស្វ៊ីតនៃចំនួនពិតគឺជា អនុគមន៍លេខដែលកំណត់ពី $\mathbb{N}$ ទៅ $\mathbb{R}$ ។

គេកំណត់សរសេរស្វ៊ីតដោយ $(a_n)$ ឬ $(a_n)_{n\in\mathbb{N}}$ ឬ $\{a_n\}$ : $a_n = f(n)$ ។

ឧទាហរណ៍៖ ស្វ៊ីតខាងក្រោមនេះ ជាស្វ៊ីតនៃចំនួនពិត៖

$$a_n = n^2\ ,\quad b_n = \frac{n}{n+1},\quad c_n = \sqrt{\ln n}\ ,\quad u_n = \frac{e^n}{n}$$ ។

**សម្គាល់:**

- គ្រប់ធាតុនៅក្នុងចន្លោះ $(a_1, a_2, a_3, \cdots, a_n)$ ហៅថាតួនៃស្វ៊ីត ដែល $a_1$ ហៅថាតួទី១, $a_2$ ហៅថាតួទី២ ,..., $a_n$ ហៅថាតួទី $n$ ។
- ស្វ៊ីតដែលមានតួរាប់អស់ ហៅថា ស្វ៊ីតរាប់អស់ (ស្វ៊ីតកំណត់)។
- ស្វ៊ីតដែលមានតួរាប់មិនអស់ ហៅថាស្វ៊ីតអនន្តតួ(ស្វ៊ីតមិនកំណត់)

ឧទាហរណ៍ : $(a_n):1,2,3,4,5,6,7$ ជាស្វ៊ីតរាប់អស់ ឬ ស្វ៊ីតកំណត់។

$(a_n):1,3,9,\ldots,19683$ ជាស្វ៊ីតរាប់អស់ ឬ ស្វ៊ីតកំណត់។

$(a_n):5,10,15,20,25,\ldots$ ជាស្វ៊ីតអនន្តតួ ឬ ស្វ៊ីតមិនកំណត់។

លំហាត់គំរូទី១ : បំពេញតួនៃស្វ៊ីតខាងក្រោមឱ្យបានបីតួទៀត:

ក. $3, 5, 7, 9, \ldots$

ខ. $1, 3, 6, 10, \ldots$

គ. $3, 8, 15, \ldots$

ឃ. $2, 4, 8, 16, \ldots$

ង. $1, 8, 27, 64, \ldots$

ច. $1, 1, 2, 3, 5, 8, 13, \ldots$

ឆ. $-1, 2, -3, 4, -5, \ldots$

ជ. $-1, \frac{1}{2}, -3, \frac{1}{4}, -5, \ldots$

ឈ. $9, 6, 3, \ldots$

ញ. $\frac{1}{2}, \frac{5}{6}, \frac{7}{6}, \ldots$

## ដំណោះស្រាយ

ក. $3, 5, 7, 9, \ldots$

$a_1 = 3$

$a_2 = 5 = 3 + 2$

$a_3 = 7 = 5 + 2$

$a_4 = 9 = 7 + 2$

$\Rightarrow a_5 = a_4 + 2 = 9 + 2 = 11$

$\Rightarrow a_6 = a_5 + 2 = 11 + 2 = 13$

$\Rightarrow a_7 = a_6 + 2 = 13 + 2 = 15$

ដូចនេះ បីតួបន្ទាប់គឺ **11 , 13 , 15**

ខ. $1, 3, 6, 10, \ldots$

$a_1 = 1$

$a_2 = 3 = a_1 + 2$

$a_3 = 6 = a_2 + 3$

$a_4 = 10 = a_3 + 4$

$\Rightarrow a_5 = a_4 + 5 = 10 + 5 = 15$

$\Rightarrow a_6 = a_5 + 6 = 15 + 6 = 21$

$\Rightarrow a_7 = a_6 + 7 = 21 + 7 = 28$

ដូចនេះ បីតួបន្ទាប់គឺ **15 , 21 , 28**

គ. $3, 8, 15, \ldots$

$a_1 = 3 = 2^2 - 1$

$a_2 = 8 = 3^2 - 1$

$a_3 = 15 = 4^2 - 1$

$\Rightarrow a_4 = 5^2 - 1 = 24$

$\Rightarrow a_5 = 6^2 - 1 = 35$

$\Rightarrow a_6 = 7^2 - 1 = 48$

ដូចនេះ បីតួបន្ទាប់គឺ **24 , 35 , 48**

## ចម្លើយ ពី ឃ ដល់ ញ

ឃ. $32, 64, 128$

ង. $125, 216, 343$

ច. $21, 34, 55$

ឆ. $6, -7, 8$

ជ. $\frac{1}{6}, 7, \frac{1}{8}$

ឈ. $0, -3, -6$

ញ. $\frac{3}{2}, \frac{11}{6}, \frac{13}{6}$

លំហាត់គំរូទី២ : សរសេរគ្រប់តួនៃស្វ៊ីតរាប់អស់ដែលកំណត់ដូចខាងក្រោមះ

ក. $a_n = \frac{1}{n+2}$ ដែល $1 \le n \le 4$

ខ. $a_n = \frac{(-1)^n}{n}$ ដែល $1 \le n \le 8$

គ. $a_n = 3n - 1$ ដែល $1 \le n \le 4$

ឃ. $a_n = 2^{-n+2}$ ដែល $1 \le n \le 5$

ច. $a_n = 2^n - 1$ ដែល $1 \le n \le 6$

ឆ. $a_n = \frac{(-1)^n}{n+1}$ ដែល $1 \le n \le 5$

ឃ. $a_n=\dfrac{n-4}{n(n+2)}$ ដែល $1\le n\le 4$

## ដំណោះស្រាយ

ក. $a_n=\dfrac{1}{n+2}$ ដែល $1\le n\le 4$

ជំនួស $n=1,2,3,4$ យើងបាន:

$$a_1=\frac{1}{1+2}=\frac{1}{3}$$

$$a_2=\frac{1}{2+2}=\frac{1}{4}$$

$$a_3=\frac{1}{3+2}=\frac{1}{5}$$

$$a_4=\frac{1}{4+2}=\frac{1}{6}$$

ដូចនេះ បួនតួដែលត្រូវកំណត់គឺ $\boxed{\frac{1}{3},\frac{1}{4},\frac{1}{5},\frac{1}{6}}$

ខ. $a_n=\dfrac{(-1)^n}{n}$ ដែល $1\le n\le 8$

ជំនួស $n=1,2,3,4,5,6,7,8$ យើងបាន:

$$a_1=\frac{(-1)^1}{1}=-1 \qquad a_5=\frac{(-1)^5}{5}=-\frac{1}{5}$$

$$a_2=\frac{(-1)^2}{2}=-\frac{1}{2} \qquad a_6=\frac{(-1)^6}{6}=\frac{1}{6}$$

$$a_3=\frac{(-1)^3}{3}=-\frac{1}{3} \qquad a_7=\frac{(-1)^7}{7}=-\frac{1}{7}$$

$$a_4=\frac{(-1)^4}{4}=\frac{1}{4} \qquad a_8=\frac{(-1)^8}{8}=\frac{1}{8}$$

ដូចនេះ ៨តួនៃស៊ីតគឺ $\boxed{-1,\frac{1}{2},-\frac{1}{3},\frac{1}{4},-\frac{1}{5},\frac{1}{6},-\frac{1}{7},\frac{1}{8}}$

គ. $a_n = 3n - 1$ ដែល $1 \le n \le 5$

ជំនួស $n = 1, 2, 3, 4, 5$ យើងបាន៖

$$a_1 = 3\cdot 1 - 1 = 2$$
$$a_2 = 3\cdot 2 - 1 = 5$$
$$a_3 = 3\cdot 3 - 1 = 8$$
$$a_4 = 3\cdot 4 - 1 = 11$$
$$a_5 = 3\cdot 5 - 1 = 14$$

ដូចនេះ ប្រាំតួនៃស្វ៊ីតគឺ $\boxed{2, 5, 8, 11, 14}$

## ចម្លើយពី ឃ ដល់ ជ

ឃ. $2, 1, \frac{1}{2}, \frac{1}{4}, \frac{1}{8}$

ង. $-1, 1, -1, 1$

ច. $1, 3, 7, 15, 31, 63$

ឆ. $-\frac{1}{2}, \frac{1}{3}, -\frac{1}{4}, \frac{1}{5}, -\frac{1}{6}$

ជ. $-1, -\frac{1}{4}, -\frac{1}{15}, 0, \frac{1}{35}$ ។

លំហាត់គំរូទី៣ : សរសេរតួនៃស្វ៊ីតលំដាប់តគ្នា៖

ក. $a_n = 2 + \frac{1}{2^n}$ , $n \in \mathbb{N}$

ខ. $a_n = 2n + 3$ , $n \in \mathbb{N}$

គ. $a_n = 2^n$ , $n = 1, 2, 3, \ldots$

ឃ. $a_n = \frac{1}{2n-1}$ , $n \in \mathbb{N}$

ង. $a_n = \frac{2n-1}{2n+1}$ , $n \in \mathbb{N}$

ច. $a_n = \frac{1}{2n}$

ឆ. $a_n = \frac{n}{2^n}$ , $n \in \mathbb{N}$

ជ. $a_n = \frac{n}{n^2+1}$ , $n \in \mathbb{N}$

ឈ. $a_n = \frac{1}{\sqrt{n}}$ , $n \in \mathbb{N}$

ញ. $a_n = e^n$ , $n \in \mathbb{N}$

## ដំណោះស្រាយ

ក. $a_n = 2 + \frac{1}{2^n} = \frac{2^{n+1}+1}{2^n}$

ជំនួស $n=1,2,3,\ldots$ យើងបាន:

$$a_1=\frac{2^2+1}{2}=\frac{5}{2}$$

$$a_2=\frac{2^3+1}{2^2}=\frac{9}{4}$$

$$a_3=\frac{2^4+1}{2^3}=\frac{17}{8}$$

$$a_4=\frac{2^5+1}{2^4}=\frac{33}{16}$$

...........................

ដូចនេះ $\boxed{(a_n):\frac{5}{2},\frac{9}{4},\frac{17}{8},\frac{33}{16},\ldots,2^n+\frac{1}{2^n},\ldots}$ ចំពោះ $n\in\mathbb{N}$

ខ. $a_n=2n+3$

ជំនួស $n=1,2,3,\ldots$ យើងបាន:

$$a_1=2\cdot1+3=5$$

$$a_2=2\cdot2+3=7$$

$$a_3=2\cdot3+3=9$$

$$a_4=2\cdot4+3=11$$

..........................

ដូចនេះ $\boxed{(a_n):5,7,9,11,\ldots,2n+3,\ldots}$ ចំពោះ $n\in\mathbb{N}$

គ. $a_n=2^n$

ជំនួស $n=1,2,3,4,\ldots$ យើងបាន:

$a_1=2^1=1$ $\quad$ $a_2=2^2=4$

$a_3=2^3=8$ $\quad$ $a_4=2^4=16$

.............................................................

ដូចនេះ $\boxed{(a_n):2,4,8,16,\ldots,2^n,\ldots}$ ចំពោះ $n\in\mathbb{N}$

## ចម្លើយ ពី ឃ ដល់ ញ

ឃ. $(a_n):1,\frac{1}{3},\frac{1}{5},\frac{1}{7},\dots,\frac{1}{2n-1},\dots$

ង. $(a_n):\frac{1}{3},\frac{3}{5},\frac{5}{7},\frac{7}{9},\dots,\frac{2n-1}{2n+1},\dots$

ច. $(a_n):\frac{1}{2},\frac{1}{4},\frac{1}{6},\frac{1}{8},\dots,\frac{1}{2n},\dots$

ឆ. $(a_n):\frac{1}{2},\frac{1}{2},\frac{3}{8},\frac{1}{4},\frac{5}{32},\dots,\frac{n}{2^n},\dots$

ជ. $(a_n):\frac{1}{2},\frac{2}{5},\frac{3}{10},\frac{4}{17},\frac{5}{26},\dots,\frac{n}{n^2+1},\dots$

ឈ. $(a_n):1,\frac{1}{\sqrt{2}},\frac{1}{\sqrt{3}},\frac{1}{2},\dots,\frac{1}{\sqrt{n}},\dots$

ញ. $(a_n):e,e^2,e^3,e^4,\dots,e^n,\dots$

## ២. តួទី n នៃស្វ៊ីត

ឧទាហរណ៍: គេឱ្យស្វ៊ីត $(a_n):3,9,27,81,243$ ដែល $n\in\mathbb{N}$

យើងសង្កេតឃើញថា: $a_1=3=3^1$

$a_2=9=3^2$

$a_3=27=3^3$

$a_4=81=3^4$

$a_5=243=3^5$

....................

$\Rightarrow a_n=3^n$

យើងបាន $3^n$ ជាតួទី $n$ នៃស្វ៊ីត $(a_n)$

គេសរសេរ $a_n=3^n$ ហៅថាតួទី $n$ (ឬតួទូទៅ)នៃស្វ៊ីត។

លំហាត់គំរូទី១ : កំណត់តួទី $n$ នៃស្វ៊ីត: $\frac{1}{2},\frac{1}{4},\frac{1}{8},\frac{1}{16},\cdots$ ។

## ដំណោះស្រាយ

យើងមានៈ $a_1 = \frac{1}{2} = \frac{1}{2^1}$

$a_2 = \frac{1}{4} = \frac{1}{2^2}$

$a_3 = \frac{1}{8} = \frac{1}{2^3}$

$a_4 = \frac{1}{16} = \frac{1}{2^4}$

...................

$\Rightarrow a_n = \frac{1}{2^n}$

ដូចនេះ តួទី $n$ នៃស្វ៊ីតគឺ $\boxed{a_n = 2^n}$ ចំពោះគ្រប់ $n \in \mathbb{N}$

លំហាត់គំរូទី២ : កំណត់តួទី $n$ នៃស្វ៊ីត $2, 5, 10, 17, \ldots$ ។

## ដំណោះស្រាយ

យើងមាន់ៈ $a_1 = 2 = 1^2 + 1$

$a_2 = 5 = 2^2 + 1$

$a_3 = 10 = 3^2 + 1$

$a_4 = 17 = 4^2 + 1$

.........................

$\Rightarrow a_n = n^2 + 1$

ដូចនេះ តួទី $n$ នៃស្វ៊ីតគឺ $\boxed{a_n = n^2 + 1}$ ចំពោះគ្រប់ $n \in \mathbb{N}$

លំហាត់គំរូទី៣ : កំណត់តួទី $n$ នៃស្វ៊ីតៈ $-1, 2, 7, 14, 23,$ ។

## ដំណោះស្រាយ

យើងមានៈ $a_1 = -1 = 1^2 - 2$

$a_2 = 2 = 2^2 - 2$

$a_3 = 7 = 3^2 - 2$

$a_4 = 14 = 4^2 - 2$

$a_5 = 23 = 5^2 - 2$

........................

$\Rightarrow a_n = n^2 - 2$

ដូចនេះ តួទី $n$ នៃស្វីតគឺ $\boxed{a_n = n^2 - 2}$ ចំពោះគ្រប់ $n \in \mathbb{N}$

លំហាត់គំរូទី៤ : កំណត់តួទី $n$ នៃស្វីត: $\frac{2}{3}, \frac{3}{4}, \frac{4}{5}, \frac{5}{6}, \ldots$ ។

## ដំណោះស្រាយ

យើងមាន: $a_1 = \frac{2}{3} = \frac{1+1}{1+2}$

$a_2 = \frac{3}{4} = \frac{2+1}{2+2}$

$a_3 = \frac{4}{5} = \frac{3+1}{3+2}$

$a_4 = \frac{5}{6} = \frac{4+1}{4+2}$

......................

$\Rightarrow a_n = \frac{n+1}{n+2}$

ដូចនេះ តួទី $n$ នៃស្វីតគឺ $\boxed{a_n = \frac{n+1}{n+2}}$ ចំពោះគ្រប់ $n \in \mathbb{N}$

## លំហាត់អនុវត្តន៍

កំណត់តួទី $n$ ចំពោះគ្រប់ $n \in \mathbb{N}$ នៃស្វីតខាងក្រោម:

ក. $-3, -5, -7, -9, \ldots$ ខ. $-3, -1, 1, 3, 5, \ldots$

គ. $16,13,10,7,4,\ldots$

ឃ. $5,7,9,11,13,\cdots$

ង. $\frac{2}{3},\frac{3}{5},\frac{4}{7},\frac{5}{9},\ldots$

ច. $\frac{1}{3},\frac{3}{5},\frac{7}{9},\frac{15}{17},\frac{31}{33},\ldots$

ឆ. $-\frac{1}{3},\frac{1}{5},-\frac{1}{7},\frac{1}{9},\ldots$

ជ. $\frac{1}{3},\frac{1}{8},\frac{1}{15},\frac{1}{24},\ldots$

ឈ. $\frac{1}{2},\frac{2}{5},\frac{3}{10},\frac{4}{17},\ldots$

ញ. $\frac{1}{3},\frac{2}{5},\frac{3}{9},\frac{4}{17},\ldots$

ដ. $-1,1,-1,1,\ldots$

ឋ. $1,\frac{1}{2},3,\frac{1}{4},5,\ldots$

ឌ. $1,\frac{1}{4},\frac{1}{9},\frac{1}{16},\ldots$

ឍ. $\frac{3}{4},\frac{4}{9},\frac{5}{16},\frac{6}{25},\ldots$

ណ. $\frac{1}{2},\frac{1}{6},\frac{1}{12},\frac{1}{20},\ldots$

ត. $\frac{1}{1\cdot 4},\frac{1}{4\cdot 7},\frac{1}{7\cdot 10},\frac{1}{10\cdot 13},\ldots$

ថ. $\frac{3}{2^2\cdot 3^2},\frac{5}{3^2\cdot 4^2},\frac{7}{4^2\cdot 5^2},\frac{9}{5^2\cdot 6^2},\ldots$

ទ. $\frac{3}{4},\left(\frac{6}{7}\right)^2,\left(\frac{9}{10}\right)^2,\left(\frac{12}{13}\right)^2\ldots$

# ៣. អថេរភាពនៃស្វ៊ីត

## ៣.១ ស្វ៊ីតកើន ស្វ៊ីតចុះ

### ក. និយមន័យ

- ស្វ៊ីត $(a_n)$ ជាស្វ៊ីតកើន លុះត្រាតែ $a_n \le a_{n+1}$ ចំពោះគ្រប់ $n\in\mathbb{N}$ ។
- ស្វ៊ីត $(a_n)$ ជាស្វ៊ីតចុះ លុះត្រាតែ $a_n \ge a_{n+1}$ ចំពោះគ្រប់ $n\in\mathbb{N}$ ។
- បើ $a_n < a_{n+1}$ ចំពោះគ្រប់ $n\in\mathbb{N}$ នោះ $(a_n)$ ជាស្វ៊ីតកើនដាច់ខាត
- បើ $a_n \ge a_{n+1}$ ចំពោះគ្រប់ $n\in\mathbb{N}$ នោះ $(a_n)$ ជាស្វ៊ីតចុះដាច់ខាត។

### ខ. របៀបសិក្សាអថេរភាពស្វ៊ីត

របៀបទី១: សិក្សាសញ្ញានៃផលដក $a_{n+1}-a_n$ ធៀបនឹង $0$

- បើ $a_{n+1}-a_n\ge 0\Leftrightarrow a_{n+1}\ge a_n$ , $\forall n\in\mathbb{N}$ នោះ $(a_n)$ ជាស៊ីតកើន
- បើ $a_{n+1}-a_n\le 0\Leftrightarrow a_{n+1}\le a_n$ , $\forall n\in\mathbb{N}$ នោះ $(a_n)$ ជាស៊ីតចុះ
- បើ $a_{n+1}-a_n> 0\Leftrightarrow a_{n+1}> a_n$ , $\forall n\in\mathbb{N}$ នោះ $(a_n)$ ជាស៊ីតកើនដាច់ខាត
- បើ $a_{n+1}-a_n< 0\Leftrightarrow a_{n+1}< a_n$ , $\forall n\in\mathbb{N}$ នោះ $(a_n)$ ជាស៊ីចុះដាច់ខាត
- បើ $a_{n+1}-a_n= 0\Leftrightarrow a_{n+1}= a_n$ , $\forall n\in\mathbb{N}$ នោះ $(a_n)$ ជាស៊ីតថេរ
- បើ $a_{n+1}-a_n$ មានសញ្ញាមិនថេរ $\forall n\in\mathbb{N}$ នោះ $(a_n)$ មិនមែនជាស៊ីតកើន ហើយក៏មិនមែនជាស៊ីតចុះដែរ ។

លំហាត់គំរូទី១ : សិក្សាភាពកើន ឬ ចុះនៃស៊ីតខាងក្រោមៈ

ក. ស៊ីត $(a_n)_{n\in\mathbb{N}}$ ដែល $a_n=5n+3$ ។

ខ. ស៊ីត $(a_n)_{n\ge 5}$ ដែល $a_n=\dfrac{3n}{2}$ ។

គ. ស៊ីត $(a_n)_{n\ge 3}$ ដែល $a_n=\dfrac{2}{n}$ ។

## ដំណោះស្រាយ

ក. យើងមាន $a_n=5n+3\Rightarrow a_{n+1}=5(n+1)+3=5n+8$

យើងបាន $a_{n+1}-a_n=(5n+8)-(5n+3)=5>0$

$\Rightarrow a_{n+1}>a_n$ ចំពោះគ្រប់ $n\in\mathbb{N}$

ដូចនេះ ស៊ីត $(a_n)_{n\in\mathbb{N}}$ ដែល $a_n=5n+3$ ជាស៊ីតកើន

ខ. យើងមាន $a_n=\dfrac{3n}{2}\Rightarrow a_{n+1}=\dfrac{3(n+1)}{2}=\dfrac{3n}{2}+\dfrac{3}{2}$

យើងបាន $a_{n+1}-a_n=\left(\dfrac{3n}{2}+\dfrac{3}{2}\right)-\dfrac{3n}{2}=\dfrac{3}{2}>0$

$\Rightarrow a_{n+1}>a_n$ ចំពោះគ្រប់ $n\ge 5$

ដូចនេះ ស៊ីត $(a_n)_{n\geq 5}$ ដែល $a_n=\dfrac{3n}{2}$ ជាស៊ីតកើន

គ. យើងមាន $a_n=\dfrac{2}{n}\Rightarrow a_{n+1}=\dfrac{2}{n+1}$

យើងបាន $a_{n+1}-a_n=\dfrac{2}{n+1}-\dfrac{2}{n}$

$$=\frac{2n-2n-2}{n(n+1)}$$

$$=-\frac{2}{n(n+1)}<0 \text{ ចំពោះគ្រប់ } n\geq 3$$

ដូចនេះ ស៊ីត$(a_n)_{n\geq 3}$ ដែល $a_n=\dfrac{2}{n}$ ជាស៊ីតចុះ

លំហាត់គំរូទី២: សិក្សាភាពកើន ចុះ នៃស៊ីតខាងក្រោម:

ក. $a_n=n^2-3n+2 \quad ,n\in\mathbb{N}$

ខ. $a_n=-n^2+7n-12 \quad ,n\geq 3$

គ. $a_n=\dfrac{n^2-3n+6}{2} \quad ,n\in\mathbb{N}$

**ដំណោះស្រាយ**

ក. យើងមាន $a_n=n^2-3n+2\Rightarrow a_{n+1}=(n+1)^2-3(n+1)+2=n^2-n$

យើងបាន $a_{n+1}-a_n=(n^2-n)-(n^2-3n+2)$

$$=2n-2$$

$$=n(n-1)\geq 0,\ \forall n\in\mathbb{N}$$

នោះ $a_{n+1}\geq a_n$ ចំពោះគ្រប់ $n\in\mathbb{N}$

ដូចនេះ ស៊ីត$(a_n)$ ដែល $a_n=n^2-3n+2 \quad ,n\in\mathbb{N}$ ជាស៊ីតកើន

ខ. យើងមាន $a_n=-n^2-7n-12$

$$\Rightarrow a_{n+1}=-(n+1)^2-7(n+1)-12=-n^2+5n-6$$

យើងបាន $a_{n+1}-a_n=(-n^2+5n-6)-(-n^2+7n-12)$

$$=-2(n-3)\le 0\,,\forall n\ge 3\,,n\in\mathbb{N}$$

នាំឱ្យ $a_{n+1}\le a_n$ , $\forall n\ge 3$ , $n\in\mathbb{N}$

ដូចនេះ ស៊ីត $\left(a_n\right)_{n\ge 3}$ ដែល $a_n=-n^2+7n-12$ ជាស៊ីតចុះ

គ. យើងមាន $a_n=\dfrac{n^2-3n+6}{2}$

$$\Rightarrow a_{n+1}=\frac{(n+1)^2-3(n+1)+6}{2}=\frac{n^2-n+4}{4}$$

យើងបាន $a_{n+1}-a_n=\dfrac{n^2-n+4}{2}-\dfrac{n^2-3n+6}{2}=n-1\ge 0$ , $\forall n\in\mathbb{N}$

$$\Rightarrow a_{n+1}\ge a_n \ ,\forall n\in\mathbb{N}$$

ដូចនេះ ស៊ីត $\left(a_n\right)$ ដែល $a_n=\dfrac{n^2-3n+6}{2}$ ជាស៊ីតកើន

លំហាត់គំរូទី២ : សិក្សាអថេរភាពនៃស៊ីត$\left(a_n\right)_{n\in\mathbb{N}}$ ដែល $a_n=\left(-2\right)^n$ ។

**ដំណោះស្រាយ**

យើងមាន $a_n=\left(-2\right)^n \Rightarrow a_{n+1}=\left(-2\right)^{n+1}=-2\cdot\left(-2\right)^n$

យើងបាន $a_{n+1}-a_n=-2\cdot(-2)^n-(-2)^n=-3\cdot(-2)^n$ មានសញ្ញាមិនថេរ ចំពោះគ្រប់ $n\in\mathbb{N}$

ដូចនេះ ស៊ីត$\left(a_n\right)_{n\in\mathbb{N}}$ ដែល $a_n=\left(-2\right)^n$ មិនមែនជាស៊ីតកើន ហើយ ក៏មិនមែនជាស៊ីតចុះដែរ

## **របៀបទី២** :

បើស៊ីត $\left(a_n\right)$មានតួវិជ្ជមានដាច់ខាត គេប្រាប់ធៀប $\dfrac{a_{n+1}}{a_n}$ ទៅនឹងចំនួន 1

- ស៊ីត$(a_n)$ ជាស៊ីតកើនលុះត្រាតែ $\frac{a_{n+1}}{a_n}\geq 1$ ចំពោះ $\forall n\in\mathbb{N}$ ។
- ស៊ីត $(a_n)$ ជាស៊ីតចុះ លុះត្រាតែ $\frac{a_{n+1}}{a_n}\leq 1$ ចំពោះ $\forall n\in\mathbb{N}$ ។
- បើ $\frac{a_{n+1}}{a_n}=1$ ចំពោះ $\forall n\in\mathbb{N}$ នោះ $(a_n)$ ជាស៊ីតថេរ។

លំហាត់គំរូទី៣ : សិក្សាអថេរភាពនៃស៊ីត $(a_n)$ ដូចខាងក្រោម៖

ក. $a_n=3^n$ , $\forall n\in\mathbb{N}$ ។

ខ. $a_n=\left(\frac{2}{3}\right)^n$ , $\forall n\in\mathbb{N}$

## ដំណោះស្រាយ

ក. យើងមាន $a_n=3^n \Rightarrow a_{n+1}=3^{n+1}=3\cdot 3^n$

យើងបាន $\frac{a_{n+1}}{a_n}=\frac{3\cdot 3^n}{3^n}=3>1 \Rightarrow a_{n+1}>a_n$

ដូចនេះ ស៊ីត $(a_n)$ ដែល $a_n=3^n$ , $\forall n\in\mathbb{N}$ ជាស៊ីតកើន

ខ. យើងមាន $a_n=\left(\frac{2}{3}\right)^n \Rightarrow a_{n+1}=\left(\frac{2}{3}\right)^{n+1}=\frac{2}{3}\cdot\left(\frac{2}{3}\right)^n$

យើងបាន $\frac{a_{n+1}}{a_n}=\frac{\frac{2}{3}\cdot\left(\frac{2}{3}\right)^n}{\left(\frac{2}{3}\right)^n}=\frac{2}{3}<1 \Rightarrow a_{n+1}<a_n$

ដូចនេះ ស៊ីត $(a_n)$ ដែល $a_n=\left(\frac{2}{3}\right)^n$ , $\forall n\in\mathbb{N}$ ជាស៊ីតចុះ

# លំហាត់អនុវត្តន៍

១. បង្ហាញថា ស្វ៊ីត $(a_n)$ ដែល $a_n = \dfrac{1}{n+2}$ ជាស្វ៊ីតចុះ ។

២. បង្ហាញថា ស្វ៊ីត$(a_n)$ ដែល $a_n = \dfrac{2n+1}{n+3}$ ជាស្វ៊ីតកើន។

៣. សិក្សាភាពកើន ចុះ នៃស្វ៊ីត$(a\ )$ ដែល$a_n = \dfrac{3n-1}{2n+3}$ , $n \in \mathbb{N}$ ។

៤. សិក្សាអថេរភាពនៃស្វ៊ីតខាងក្រោម:

ក. $a_n = \dfrac{n}{n+1}$ , $n \in \mathbb{N}$

ខ. $a_n = \dfrac{2n}{3n+1}$ , $n \in \mathbb{N}$

គ. $a_n = \dfrac{1}{n^3}$ , $n \in \mathbb{N}$

ឃ. $a_n = \dfrac{1}{2^n}$ , $n \in \mathbb{N}$

ង. $a_n = -\dfrac{1}{n}$ , $n \in \mathbb{N}$

ច. $a_n = \dfrac{n-1}{n^2}$ , $n = 2, 3, 4, \ldots$

៥. រកតម្លៃ $k$ ដើម្បីឱ្យស្វ៊ីត $(a_n)$ ដែល $a_n = \dfrac{n+k}{n+1}$ ជាស្វ៊ីតកើន។

៦. បង្ហាញថាស្វ៊ីត$(a_n)$ ដែល$a_n = \dfrac{3n}{4n-5}$ ជាស្វ៊ីតចុះ ចំពោះ $n = 2,3,4,\ldots$

៧. សិក្សាភាពកើន ចុះ នៃស្វ៊ីតខាងក្រោម:

ក. $a_n = n^2 - 9n + 20$ , $n = 4, 5, 6, \ldots$

ខ. $a_n = \dfrac{n}{e^n}$ , $n \in \mathbb{N}$

គ. $a_n = |c|^n$ , $n \in \mathbb{N}$

ឃ. $a_n = 5^{-n}$ , $n \in \mathbb{N}$

ង. $a_n = \left(3^n + 4^n\right)^{\frac{1}{n}}$ , $n \in \mathbb{N}$

## ៣.២. ស៊ីតម៉ូណូតូន

**និយមន័យ** ស៊ីត$(a_n)$ជាស៊ីតម៉ូណូតូនលុះត្រាតែ $a_n \le a_{n+1}$ , $\forall n \in \mathbb{N}$ ( ឬ $a_1 \le a_2 \le a_3 \le \ldots \le a_n \le a_{n+1} \le \ldots$) ឬ $a_n \ge a_{n+1}$ ចំពោះគ្រប់ $n \in \mathbb{N}$ ( ឬ $a_1 \ge a_2 \ge a_3 \ge \ldots \ge a_n \ge a_{n+1} \ge \ldots$ )។

**សម្គាល់** :

- ស៊ីតកើន ឬ ស៊ីតចុះជាស៊ីតម៉ូណូតូន។ ដូចនេះ ដើម្បីបង្ហាញថាស៊ីត$(a_n)$ ជាស៊ីតម៉ូណូតូន យើងត្រូវបង្ហាញថា$(a_n)$ជាស៊ីតកើន ឬ ស៊ីតចុះ ។
- បើស៊ីត $(a_n)$មិនមែនជាស៊ីតកើន ឬ មិនមែនជាស៊ីតចុះ នោះ $(a_n)$ មិនមែនជាស៊ីតម៉ូណូតូនទេ។
- **ស៊ីតថេរ ក៏ជាស៊ីតម៉ូណូតូនដែរ**

លំហាត់គំរូទី១ : បង្ហាញថាស៊ីត $(a_n)_{n\in\mathbb{N}}$ ដែល $a_n = \dfrac{1}{2^n}$ ជាស៊ីតម៉ូណូតូន។

**ដំណោះស្រាយ**

របៀបទី១

យើងមាន $a_n = \dfrac{1}{2^n} \Rightarrow a_{n+1} = \dfrac{1}{2^{n+1}} = \dfrac{1}{2}\cdot\dfrac{1}{2^n}$

យើងបាន $\dfrac{a_{n+1}}{a_n} = \dfrac{\frac{1}{2}\cdot\frac{1}{2^n}}{\frac{1}{2^n}} = \dfrac{1}{2} < 1 \Rightarrow a_{n+1} < a_n$ , $\forall n \in \mathbb{N}$

ដូចនេះ ស៊ីត $(a_n)_{n\in\mathbb{N}}$ ដែល $a_n = \dfrac{1}{2^n}$ ជាស៊ីតម៉ូណូតូន(ចុះ)

របៀបទី២

យើងមាន $a_n = \dfrac{1}{2^n} \Rightarrow a_{n+1} = \dfrac{1}{2^{n+1}} = \dfrac{1}{2}\cdot\dfrac{1}{2^n}$

យើងបាន $a_{n+1}-a_n=\frac{1}{2}\cdot\frac{1}{2^n}-\frac{1}{2^n}=-\frac{1}{2^n}<0\ ,\forall n\in\mathbb{N}$

$\Rightarrow a_{n+1}<a_n$ ( $(a_n)$ ជាស្វ៊ីតចុះ)

ដូចនេះ ស្វ៊ីត $(a_n)_{n\in\mathbb{N}}$ ដែល $a_n=\frac{1}{2^n}$ ជាស្វ៊ីតម៉ូណូតូន(ចុះ)

លំហាត់គំរូទី២ : សិក្សាភាពម៉ូណូតូននៃស្វ៊ីតខាងក្រោម៖

ក. $a_n=\frac{2^n}{n}\ ,n\ge 1$

ខ. $a_n=\frac{4n}{n+1}\ ,n\in\mathbb{N}$

គ. $1,-\frac{1}{2},\frac{1}{3},-\frac{1}{4},\ldots,(-1)^{n+1}\cdot\frac{1}{n}$

ឃ. $1,\frac{1}{2},\frac{1}{3},\ldots,\frac{1}{n}$

**ដំណោះស្រាយ**

ក. យើងមាន $a_n=\frac{2^n}{n}\ ,n\ge 1$

$\Rightarrow a_{n+1}=\frac{2^{n+1}}{n+1}=\frac{2\cdot 2^n}{n+1}$

យើងបាន $\Rightarrow a_{n+1}-a_n=\frac{2\cdot 2^n}{n+1}-\frac{2^n}{n}$

$=\frac{2n\cdot 2^n-n\cdot 2^n-2^n}{n(n+1)}$

$=\frac{(n-1)\cdot 2^n}{n(n+1)}\ge 0$ ចំពោះគ្រប់ $n\ge 1$

$\Rightarrow a_{n+1}\ge a_n$ ចំពោះគ្រប់ $n\ge 1$

ដូចនេះ ស្វ៊ីត$(a_n)$ ដែល $a_n=\frac{2^n}{n}\ ,n\ge 1$ ជាស្វ៊ីតម៉ូណូតូន(កើន)

ខ. យើងមាន $a_n = \dfrac{4n}{n+1}\ ,n \in \mathbb{N}$

$$\Rightarrow a_{n+1} = \frac{4(n+1)}{(n+1)+1} = \frac{4n+4}{n+2}$$

យើងបាន $a_{n+1} - a_n = \dfrac{4n+4}{n+2} - \dfrac{4n}{n+1}$

$$= \frac{4n^2+4n+4n+4-4n^2-8n}{(n+1)(n+2)}$$

$$= \frac{4}{(n+1)(n+2)} > 0\ ,\ \forall n \in \mathbb{N}$$

$$\Rightarrow a_{n+1} > a_n\ ,\ \forall n \in \mathbb{N}$$

ដូចនេះ ស្វ៊ីត $(a_n)$ ដែល $a_n = \dfrac{4n}{n+1}\ ,n \in \mathbb{N}$ ជាស្វ៊ីតម៉ូណូតូន(កើន)

គ. យើងមាន $a_n = (-1)^{n+1} \cdot \dfrac{1}{n}$

$$\Rightarrow a_{n+1} = (-1)^{n+2} \cdot \frac{1}{n+1} = -(-1)^{n+1} \cdot \frac{1}{n+1}$$

យើងបាន $a_{n+1} - a_n = -(-1)^{n+1} \cdot \dfrac{1}{n+1} - (-1)^n \cdot \dfrac{1}{n}$

$$= (-1)^n \left( -\frac{1}{n+1} - \frac{1}{n} \right)$$

$= (-1)^n \cdot \dfrac{2n+1}{n(n+1)}$ មានសញ្ញាមិនថេរ $\forall n \in \mathbb{N}$

នោះ $(a_n)$ មិនមែនជា ស្វ៊ីតកើន ចុះ ឬ ថេរទេ

ដូចនេះ ស្វ៊ីត$1, -\dfrac{1}{2}, \dfrac{1}{3}, -\dfrac{1}{4}, \ldots, (-1)^{n+1} \cdot \dfrac{1}{n}$ មិនមែនជាស្វ៊ីតម៉ូណូតូនទេ

ឃ. $1, \dfrac{1}{2}, \dfrac{1}{3}, \ldots, \dfrac{1}{n}$

យើងមាន $a_1 = 1, a_2 = \dfrac{1}{2}, a_3 = \dfrac{1}{3}, \ldots, a_n = \dfrac{1}{n}$

នោះ $a_1 > a_2 > a_3 > \ldots > a_n > a_{n+1} > \ldots$

ដូចនេះ ស្ទីត$1, \frac{1}{2}, \frac{1}{3}, \ldots, \frac{1}{n}$ ជាស្ទីតម៉ូណូតូន(ចុះ)

របៀបម្យ៉ាងទៀត

យើងមាន $a_n = \frac{1}{n} \Rightarrow a_{n+1} = \frac{1}{n+1}$

យើងបាន $a_{n+1} - a_n = \frac{1}{n+1} - \frac{1}{n} = -\frac{1}{n(n+1)}) < 0$

$\Rightarrow a_{n+1} < a_n$ ( $(a_n)$ ជាស្ទីចុះ )

ដូចនេះ ស្ទីត$1, \frac{1}{2}, \frac{1}{3}, \ldots, \frac{1}{n}$ ជាស្ទីតម៉ូណូតូន(ចុះ)

## លំហាត់អនុវត្តន៍

១. សិក្សាភាពម៉ូណូតូន នៃស្ទីត$(a_n)$ ដែលកំណត់ដូចខាងក្រោមៈ

ក. $a_n = \frac{2n+5}{n+1}$

ខ. $a_n = \frac{(-1)^n}{n}$

គ. $a_n = 2^n \cdot 3^{n+1}$

ឃ. $a_n = (n-3)^2$ , $n \geq 3$

ង. $a_n = 3 + (-1)^n$

ច. $a_n = \frac{1}{n^2}$

ឆ. $a_n = (-1)^n$

ជ. $a_1 = 1$ និង $a_{n+1} = a_n - 3$

២. បង្ហាញថា ស្ទីត$(a_n)$ ដែល $a_n = \frac{\pi^n}{n}$ ជាស្ទីតម៉ូណូតូន។

៣. បង្ហាញថាស្ទីត$(a_n)$ដែល $a_n = \sqrt{2+\sqrt{2+\sqrt{2+\cdots+\sqrt{2}}}}$ ជាស្ទីតម៉ូណូតូន

# ៤. ស៊ីតទាល់

## ៤.១ ស៊ីតទាល់លើ

ឧទាហរណ៍ : គេឱ្យស៊ីត $(a_n)$ ដែល $a_n = -n^2 + 1$

គេបាន $a_1 = 0, a_2 = -3, a_3 = -8, a_4 = -15, \ldots, a_{100} = -9999, \ldots$

នោះ $0 = a_1 > a_2 > a_3 > a_4 > \cdots$ ឬ $a_n \le 0$ ចំពោះ $\forall n \in \mathbb{N}$ ។

គេថា ស៊ីតនេះ ជា**ស៊ីតទាល់លើ** ។ 0 ហៅថា**គោលលើ**នៃស៊ីតនេះ។

| | |
|---|---|
| **និយមន័យ** | ស៊ីត $(a_n)$ ជាស៊ីតទាល់លើ លុះត្រាតែមានចំនួនពិត $M$ មួយ ដែលចំពោះ $\forall n \in \mathbb{N}$ ផ្ទៀងផ្ទាត់ $a_n \le M$ ។ ចំនួន $M$ នេះ ហៅថា **គោលលើនៃស៊ីត** ។ |

លំហាត់គំរូទី១ : រកគោលលើនៃស៊ីតដែលកំណត់ដូចខាងក្រោម៖

ក. $a_n = 2^{-n}$ , $n \in \mathbb{N}$

ខ. $a_n = \dfrac{2}{n}$ , $n \in \mathbb{N}$

គ. $(a_n)$ ដែល $a_1 = 1$ និង $a_n = \dfrac{a_{n-1}}{2}$ បើ $n \ge 2$ ។

**ដំណោះស្រាយ**

ក. យើងមាន $a_n = 2^{-n} = \dfrac{1}{2^n}$

យើងបាន $a_1 = \dfrac{1}{2},\ a_2 = \dfrac{1}{4},\ a_3 = \dfrac{1}{8},\ a_4 = \dfrac{1}{16},\ \ldots$

នោះ $\dfrac{1}{2} = a_1 > a_2 > a_3 > a_4 > \cdots$

$\Rightarrow a_n \le \dfrac{1}{2}$

ដូចនេះ គោលលើនៃស៊ីតនេះគឺ $\boxed{M = \dfrac{1}{2}}$

ខ. យើងមាន $a_n = \dfrac{2}{n}$

យើងបាន $a_1 = 2\,,\ a_2 = 1\,,\ a_3 = \dfrac{2}{3}\,,\ a_4 = \dfrac{1}{2}\,,\ \ldots$

នោះ $2 = a_1 > a_2 > a_3 > a_4 > \ldots$

$\Rightarrow a_n \le 2$

ដូចនេះ គោលលើនៃស្វ៊ីតនេះគឺ $\boxed{M = 2}$

គ. យើងមាន $a_1 = 1\ ,\ a_n = \dfrac{a_{n-1}}{2}\,, n \ge 2$

យើងបាន $a_2 = \dfrac{a_1}{2} = \dfrac{1}{2}\ ,\ a_3 = \dfrac{a_2}{2} = \dfrac{1}{4}\,, a_4 = \dfrac{a_3}{2} = \dfrac{1}{8}\,,\ldots$

នោះ $1 = a_1 > a_2 > a_3 > a_4 > \ldots$

$\Rightarrow a_n \le 1$

ដូចនេះ គោលលើនៃស្វ៊ីតនេះគឺ $\boxed{M = 1}$

## ៤. ២. ស្វ៊ីតទាល់ក្រោម

ឧទាហរណ៍: គេឱ្យស្វ៊ីត$(a_n)$ ដែល $a_n = 2^n + 1\ ,\quad n \in \mathbb{N}$ ។

គេបាន $a_1 = 3\,, a_2 = 5\,, a_3 = 9\,, a_4 = 17\,,\ldots$

នោះ $3 = a_1 < a_2 < a_3 < a_4 \cdots$

$\Rightarrow a_n \ge 3\ ,\ \forall n \in \mathbb{N}$

ចំនួន 3 ហៅថា គោលក្រោមនៃស្វ៊ីត។

**និយមន័យ** ស្វ៊ីត$(a_n)$ ជាស្វ៊ីតទាល់ក្រោម លុះត្រាតែមានចំនួនពិត $m$ មួយ ដែលចំពោះ $\forall n \in \mathbb{N}$ ផ្ទៀងផ្ទាត់ $a_n \ge m$។ ចំនួន $m$ នេះ ហៅថា **គោលក្រោមនៃស្វ៊ីត** ។

លំហាត់គំរូទី២ : រកគោលក្រោមនៃស្វ៊ីត $(a_n)$ ដែលកំណត់ដូចខាងក្រោម:

ក. $a_n = 4n-1 \ , \ n\in\mathbb{N}$

ខ. $a_n = n+2 \ , \ n\in\mathbb{N}$

គ. $a_n = 2n+1 \ , \ n\in\mathbb{N}$ ។

## ដំណោះស្រាយ

ក. យើងមាន $a_n = 4n-1 \ , \ n\in\mathbb{N}$

យើងបាន $a_1=3, a_2=7, a_3=11, a_4=15, \ldots$

នោះ $3=a_1<a_2<a_3<a_4<\cdots$

$\Rightarrow a_n \geq 3 \ , \ \forall n\in\mathbb{N}$

ដូចនេះ ចំនួនទាល់ក្រោមនៃស្វ៊ីតនេះគឺ $\boxed{m=3}$

ខ. យើងមាន

$a_n = n+2 \ , n\in\mathbb{N}$

យើងបាន $a_1=3, a_2=4, a_3=5, a_4=6, \ldots$

នោះ $3=a_1<a_2<a_3<a_4<\cdots$

$\Rightarrow a_n \geq 3 \ , \ \forall n\in\mathbb{N}$

ដូចនេះ ចំនួនទាល់ក្រោមនៃស្វ៊ីតនេះគឺ $\boxed{m=3}$

គ . ចម្លើយ $m=3$

## ៣.៣ ស្វ៊ីតទាល់

ឧទាហរណ៍: គេឱ្យស្វ៊ីត $(a_n)$ ដែល $a_n = \dfrac{n}{n+1}$

យើងបាន $a_1=\dfrac{1}{2}, a_2=\dfrac{2}{3}, a_3=\dfrac{3}{4}, \ldots, a_{1000000}=\dfrac{1000000}{1000001}\approx 1, \ldots$

យើងឃើញថា $\dfrac{1}{2}$ ជាគោលក្រោមនៃស្វ៊ីត និង $1$ ជាគោលលើនៃស្វ៊ីត ព្រោះ

កាលណា តម្លៃ $n$ កាន់តែធំ( $n$ ខិតជិតអនន្ត) នោះ $\frac{n}{n+1}$ ខិតជិត $1$ ដែល $1$ ជាគោលលើនៃស្វ៊ីត។ យើងបាន ស្វ៊ីតនេះ **ទាល់លើ**ផង និង**ទាល់ក្រោម**ផង។ គេថា ស្វ៊ីត$(a_n)$ ជា**ស្វ៊ីតទាល់**។

| | |
|---|---|
| និយមន័យ | ស្វ៊ីត$(a_n)$ជាស្វ៊ីតទាល់លុះត្រាតែ$(a_n)$ជាស្វ៊ីតទាល់ខាងលើ ផង និង ទាល់ខាងក្រោមផង គឺ $m \le a_n \le M$ ។ |

លំហាត់គំរូទី៣ : បង្ហាញថា ស្វ៊ីត $(a_n)$ ដែល $a_n = \frac{1}{n^2}$ ជាស្វ៊ីតទាល់។

**ដំណោះស្រាយ**

យើងមាន $a_n = \frac{1}{n^2}$ , $n \in \mathbb{N}$

យើងបាន $a_1 = 1$ , $a_2 = \frac{1}{4}$ , $a_3 = \frac{1}{9}$ , $a_4 = \frac{1}{16}$ , …

នោះ $1 = a_1 > a_2 > a_3 > a_4 > \cdots$

$\Rightarrow a_n \le 1$ ( $M = 1$ ជាចំនួនទាល់លើ)

ម៉្យាងទៀត កាលណាតម្លៃ $n$ កាន់តែធំ$(n \to \infty)$ នោះ $a_n = \frac{1}{n^2}$ ខិតទៅរក $0$

$(\text{EX}:\ n = 100\,000\,000 \Rightarrow a_{100\,000\,000} = \frac{1}{10\,000\,000\,000\,000\,000} \approx 0\ )$

នោះ $m = 0$ ជាចំនួនទាល់ក្រោម

យើងបាន $0 \le a_n \le 1$

ដូចនេះ ស្វ៊ីត$(a_n)$ ជាស្វ៊ីតទាល់ ដែលមាន $M = 1$ ជាចំនួនទាល់លើ និង $m = 0$ ជាចំនួនទាល់ក្រោម

លំហាត់គំរូទី៤ : បណ្តាស្វ៊ីតខាងក្រោម តើស្វ៊ីតណាខ្លះ ជាស្វ៊ីតទាល់លើ ទាល់ក្រោម និង ជាស្វ៊ីតទាល់ ? រួចរកគោលនៃស្វ៊ីតនីមួយៗ ។

ក. ស្វ៊ីត $(a_n)_{n\in\mathbb{N}}$ ដែល $a_n = 1-3n$

ខ. ស្វ៊ីត $(a_n)_{n\in\mathbb{N}}$ ដែល $a_n = \frac{\pi}{n}$

គ. ស្វ៊ីត $(a_n)_{n\in\mathbb{N}}$ ដែល $a_n = \frac{3^n}{n}$ ។

## ដំណោះស្រាយ

ក. យើងមាន $a_n = 1-3n$

យើងបាន $a_1 = -2, a_2 = -5, a_3 = -8, a_4 = -11, \dots$

នោះ $-2 = a_1 > a_2 > a_3 > a_4 > \cdots \Rightarrow a_n \le -2$

$\Rightarrow$ ចំនួន $M = -2$ ជាចំនួនទាល់លើ

ម្យ៉ាងទៀត កាលណា $n \to \infty$ នោះ $a_n = 1-3n \to -\infty$ (មិនទាល់ក្រោម)

ដូចនេះ ស្វ៊ីត $(a_n)_{n\in\mathbb{N}}$ ដែល $a_n = 1-3n$ ជាស្វ៊ីតទាល់លើ ដែល $M = -2$ ជាចំនួនទាល់លើ

ខ. យើងមាន $a_n = \frac{\pi}{n}$

យើងបាន $a_1 = \pi, a_2 = \frac{\pi}{2}, a_3 = \frac{\pi}{3}, a_4 = \frac{\pi}{4}, \dots, a_{10000} = \frac{\pi}{10000}, \dots$

នោះ $\pi = a_1 > a_2 > a_3 > a_4 > \cdots \Rightarrow a_n \le \pi$

នោះ $M = 2$ ជាចំនួនទាល់លើ

ម្យ៉ាងទៀត កាលណា $n \to \infty$ នោះ $a_n = \frac{\pi}{n} \to 0$

$\Rightarrow m = 0$ ជាចំនួនទាល់ក្រោម

យើងបាន $0 \le a_n \le \pi$

ដូចនេះ ស្វ៊ីត $(a_n)_{n\in\mathbb{N}}$ ដែល $a_n = \frac{\pi}{n}$ ជាស្វ៊ីតទាល់ ដែលមាន $M = \pi$ ជាចំនួនទាល់លើ និង $m = 0$ ជាចំនួនទាល់ក្រោម។

គ. យើងមាន $a_n = \frac{3^n}{n}$

យើងបាន $a_1 = 3\ , a_2 = \frac{9}{2}, a_3 = 9, a_4 = \frac{81}{4}, \ldots$

នោះ $3 = a_1 < a_2 < a_3 < a_4 < \cdots \qquad \Rightarrow a_n \geq 3$

$\Rightarrow m = 3$ ជាចំនួនទាល់ក្រោម

ម៉្យាងទៀត បើ $n \to \infty$ នោះ $a_n = \frac{3^n}{n}$ មានតម្លៃធំមិនកំណត់បាន $(\infty)$

នោះ $(a_n)$ គ្មានចំនួនទាល់លើទេ

ដូចនេះ ស្វ៊ីត $(a_n)_{n\in\mathbb{N}}$ ដែល $a_n = \frac{3^n}{n}$ ជាស្វ៊ីតទាល់ក្រោម ដែលមាន $m = 3$ ជាចំនួនទាល់ក្រោម។

## លំហាត់អនុវត្តន៍

១. បង្ហាញថា ស្វ៊ីត$(a_n)$ ដែល $a_n = \frac{20n}{2n+1}$ ជាសស្វ៊ីតទាល់។

២. រកគោលក្រោមនៃស្វ៊ីត $(a_n)$ ដែល $a_n = \frac{e^n}{n}$

៣. តើបណ្ដាស្វ៊ីតខាងក្រោម ជាស្វ៊ីតទាល់ឬទេ ?

ក. ស្វ៊ីត$(a_n)_{n\in\mathbb{N}}$ ដែល $a_n = \frac{n^2-1}{n}$

ខ. ស្វ៊ីត$(a_n)_{n\in\mathbb{N}}$ ដែល $a_n = \frac{1}{\sqrt{n^2+1}-n}\ , n \in \mathbb{N}$

គ. ស្វ៊ីត$(a_n)_{n\in\mathbb{N}}$ ដែល $a_n = \frac{n+1}{n+3}$

ឃ. ស្វ៊ីត$(a_n)_{n\in\mathbb{N}}$ ដែល $a_n = \frac{1}{n} - \frac{1}{n+1}$

៤. បង្ហាញថា ស្វ៊ីត $(a_n)$ ដែល $a_n = \sqrt{n^4+n^2} - n^2$ ជាស្វ៊ីតទាល់។

៥.រកគោលលើនៃស្វ៊ីត $(a_n)_{n\in\mathbb{N}}$ ដែល $a_n = \frac{2n}{n+3}$ រួចបង្ហាញថា $(a_n)$ ជាស្វ៊ីតទាល់។

**ចំណាំ** : បើ $n\to\infty$ នោះយើងបាន ៖

☞ $\frac{A}{n^p}\to 0$ ដែល $A, p$ ជាចំនួនថេរ និង $p>0$

គេសរសេរ $\lim\limits_{n\to\infty}\frac{A}{n^p}=0$

☞ $\frac{An}{B}\to\infty$ , $\frac{e^n}{n^p}\to 0$ ដែល $A, B, p$ ជាចចំនួនថេរ, $p>0$

☞ $\frac{\text{មួយចំនួន}}{\infty}=0$ ហើយ $\frac{\infty}{\text{មួយចំនួន}}=\infty$ ។

☞ បើ $a_n=\frac{f(n)}{g(n)}$ ដែល $f(n)$ និង $g(n)$ ជាអនុគមន៍ពហុធា កាលណា $n\to\infty$ នោះយើងយកតែតួនៃ $f(n)$ និង $g(n)$ ដែលមានដឺក្រេខ្ពស់ជាងគេ រួចសម្រួល ។

ឧទាហរណ៏ : $a_n=\frac{n^2+2n+9}{2n^2+n-1}$

បើ $n\to\infty$ នោះ $a_n\to\frac{n^2}{2n^2}=\frac{1}{2}$

ឧទាហរណ៏ : $a_n=\frac{3n-5}{2n^2+n+1}$

បើ $n\to\infty$ នោះ $a_n\to\frac{3n}{2n^2}=\frac{3}{2n}\to 0$

ឧទាហរណ៏ : $a_n=\frac{2n^2+n-5}{n-4}$

បើ $n\to\infty$ នោះ $a_n\to\frac{2n^2}{n}=2n\to\infty$

# លំហាត់

១. សរសេរបីតួបន្ទាប់នៃស្វ៊ីតខាងក្រោម :

ក. 5, 10 , 15 , 20 , ...

ខ. 1 , 5 , 14 , 30 , 55, ...

គ. 3 , 4 , 7 , 11 , 18 , 29 , ...

ឃ. 2 , 6 , 12 , 20 , 30 , 42 , ...

២. សរសេរតួស្វ៊ីតរាប់អស់ដូចខាងក្រោម :

ក. $a_n = 3^n - n^2$ ចំពោះ $1 \le n \le 4$

ខ. $a_n = \dfrac{(-1)^n}{n(n+1)}$ ចំពោះ $1 \le n < 6$

៣. សរសេរប្រាំតួដំបូងនៃស្វ៊ីតនីមួយៗខាងក្រោម :

ក. $a_n = n^2 + n$

ខ. $a_1 = 2$ , $a_n = 2 + 3a_{n+1}$

គ. $a_1 = a_2 = 1$ , $a_{n+2} = a_{n+1} + a_n$

ឃ. $a_1 = 0$ , $a_2 = 1$ , $a_n = 3a_{n-1} - a_{n-2}$

៤. កំណត់តួទី $n$ ចំពោះគ្រប់ $n \in \mathbb{N}$ នៃស្វ៊ីតខាងក្រោម :

ក. 2,3,4,5,6...

ខ. 1 , −1 , 1 , −1 , 1 , −1 , ...

គ. 2 , 0 , 2 , 0 , 2 , 0 , ...

ឃ. $\frac{1}{3}, \frac{1}{8}, \frac{1}{15}, \frac{1}{24}, \ldots$

ង. $\frac{1}{2}, \frac{1}{6}, \frac{1}{12}, \frac{1}{20}, \ldots$

ច. $\frac{3}{4}, \frac{4}{9}, \frac{5}{16}, \frac{6}{25}, \ldots$

៥. បង្ហាញថាស៊ីត $(a_n)_{n\in\mathbb{N}}$ ដែល $a_n = \frac{1}{n+2}$ ជាស៊ីតចុះ ។

៦. បង្ហាញថាស៊ីត$(a_n)_{n\in\mathbb{N}}$ ដែល $a_n = \frac{2n+1}{n+3}$ ជាស៊ីតកើន ។

៧. រកតម្លៃ $\alpha$ ដើម្បីឱ្យស៊ីត$(a_n)$ ដែល $a_n = \frac{n+\alpha}{n+1}$ ជាស៊ីតកើន ។

៨. គេឱ្យ ស៊ីត$(a_n)$កំណត់ដោយ $a_n = 2n^2 + 1$ ។

ក. សរសេរបួនតួដំបូងនៃស៊ីតនេះ ។

ខ. តើតួទីប៉ុន្មានដែលមានតម្លៃស្មើនឹង 883 ?

៩. គេឱ្យស៊ីត$(a_n)_{n\in\mathbb{N}}$ ដែលមាន $a_1 = 0$ , $a_2 = 3$ , $a_3 = 12$ និង $a_n = xn^2 + yn + z$ ដែល $x$ , $y$ និង $z$ ជាចំនួនពិត។រកតម្លៃ $x$ , $y$ និង $z$ ។

១០. សិក្សាភាពម៉ូណូតូននៃស៊ីត$(a_n)$ដែលកំណត់ដូចខាងក្រោម :

ក. $a_n = \frac{2n+5}{n+1}$ ខ. $a_n = \frac{(-1)^n}{n+1}$

គ. $a_n = 2^n \cdot 5^{n-1}$ ឃ. $a_1 = 4$ និង $a_n = a_n - 3$ ។

១១. រកគោលក្រោម និងគោលលើនៃស៊ីត$(a_n)_{n\in\mathbb{N}}$ ដែល $a_n = \frac{8n}{2n+3}$ រួចបង្ហាញថា $(a_n)$ជាស៊ីតទាល់ ។

# មេរៀនទី ២ ស្វ៊ីតនព្វន្ត

## ១. និយមន័យនៃស្វ៊ីតនព្វន្ត

ស្វ៊ីតនព្វន្ត គឺជាស្វ៊ីតនៃចំនួនពិត ដែលតួនីមួយៗ(ក្រៅពីតួទី១) ស្មើនឹងតួមុនបន្ទាប់ បូកនឹង ចំនួនថេរ $d$ មួយហៅថាផលសងរួម ។

$$d = u_2 - u_1 = u_3 - u_2 = \cdots = u_n - u_{n-1}$$

ឧទាហរណ៍:គេឱ្យ$(u_n): 3, 6, 9, 12, \ldots$ជាស្វ៊ីតនព្វន្ត។ចូរគណនាផលសងរួម $d$ ។

ចម្លើយ $d = 6 - 3 = 3$

លំហាត់គំរូ : រកផលសងរួមនៃស្វ៊ីតនព្វន្តដែលមានតួទី១០០ ស្មើនឹង135 និង តួទី១០១ ស្មើនឹង 140 ។

**ដំណោះស្រាយ**

យើងមាន $u_{100} = 135$ និង $u_{101} = 140$

យើងបាន $d = u_{101} - u_{100} = 140 - 135 = 5$

## ២. តួទី n នៃស្វ៊ីតនព្វន្ត

បើ $(u_n)$ ជាស្វ៊ីតនព្វន្ត ដែលមានតួទីមួយ $u_1$ និងមានផលសងរួម $d$ នោះតួទី $n$ នៃស្វ៊ីតនេះគឺ $u_n = u_1 + (n-1)d$ ។

## សម្រាយ (តាមលំនាំគំរូ)

យើងមាន $d=u_n-u_{n-1} \Leftrightarrow u_n=u_{n-1}+d$

យើងបានៈ $u_2=u_1+d=u_1+(2-1)d$

$u_3=u_2+d=(u_1+d)+d=u_1+2d=u_1+(3-1)d$

$u_4=u_3+d=(u_1+2d)+d=u_1+3d=u_1+(4-1)d$

$u_5=u_4+d=(u_1+3d)+d=u_1+4d=u_1+(5-1)d$

..........................................................................

..........................................................................

..........................................................................

$\Rightarrow \mathbf{u_n=u_1+(n-1)d}$

## សម្រាយ(តាមអនុមាណរួគណិតវិទ្យា ឬ វិចារកំណើន)

ស្រាយថា $u_n=u_1+(n-1)d$

យើងមាន $u_n=u_{n-1}+d \quad (*)$

បើ $n=2$ នោះ $u_2=u_1+d=u_1+(2-1)d$ ពិត

ឧបមាថា $(*)$ ពិតដល់ $n=k$ នោះ $u_k=u_1+(k-1)d$

យើងនឹងស្រាយថា $(*)$ ពិតដល់ $n=k+1$

យើងបាន $u_{k+1}=u_k+d$

$=u_1+(k-1)d+d$

$=u_1+\left[(k+1)-1\right]d$ ពិត

ដូចនេះ តួទី $n$ នៃស្វ៊ីតនព្វន្តគឺ $\boxed{\mathbf{u_n=u_1+(n-1)d}}$

លំហាត់គំរូទី១ : គេមានស្វ៊ីតនព្វន្ត $5,10,15,20,25,...$ ។

ក. គណនាតួទី 50 នៃស្វ៊ីត ។

ខ. សរសេររូបមន្តតួទី $n$ នៃស្វ៊ីតនេះ ។

គ. តើចំនួន 555 ជាតួទីប៉ុន្មាននៃស្វ៊ីត ?

# ដំណោះស្រាយ

ក. គណនាតួទី 50 នៃស្វ៊ីត

យើងមានស្វ៊ីត

នោះ ផលសងរួម $d = 10 - 5 = 5$

$$\Rightarrow u_{50} = u_1 + (50-1)d$$
$$= 5 + (50-1)\cdot 5$$
$$= 250$$

ដូចនេះ $\boxed{u_{50} = 250}$

ខ. សរសេររូបមន្តតួទី $n$ នៃស្វ៊ីតនេះ

$$u_n = u_1 + (n-1)d$$
$$= 5 + (n-1)\cdot 5$$
$$= 5 + 5n - 5$$
$$= 5n$$

ដូចនេះ $\boxed{u_n = 5n}$

គ. រកតួដែលត្រូវនឹងចំនួន 555

តាង $n$ ចំនួនតួ ដែល $u_n = 555$

តែ $u_n = 5n$

យើងបាន $5n = 555$

$$\Rightarrow n = \frac{555}{5} = 111$$

ដូចនេះ ចំនួន 555 ត្រូវនឹងតួទី 111

លំហាត់គំរូទី២ : គេមានស៊ីតនព្វន្ត $5,12,19,26,\ldots$ ។

ក. សរសេររូបមន្តតួទី $n$ នៃស៊ីតនេះ ។

ខ. តើចំនួន 14089 តួទីប៉ុន្មាននៃស៊ីតនេះ ?

**ដំណោះស្រាយ**

ក. សរសេររូបមន្តតួទី $n$ នៃស៊ីតនេះ

យើងមាន $d=12-5=7$

យើងបាន $u_n=u_1+(n-1)d$

$=5+(n-1)\cdot 7$

$=5+7n-7$

$=7n-2$

ដូចនេះ $\boxed{u_n=7n-2}$

ខ. រកតួដែលត្រូវនឹងចំនួន 14089

តាង $n$ ជាចំនួនតួដែល $u_n=14089$

តែ $u_n=7n-2$

យើងបាន $7n-2=14089$

$7n=14091$

$\Rightarrow n=2013$

ដូចនេះ ចំនួន 14089 តួទី 2013

លំហាត់គំរូទី៣ : កំណត់ចំនួនតួនៃស៊ីតនព្វន្តខាងក្រោម ។

ក. $3,11,19,\ldots,9867$

ខ. $2000,1985,1970,\ldots,5$

គ. $6,11,16,21,\cdots,11111$

ឃ. $3,9,15,21,\cdots 597$

# ដំណោះស្រាយ

ក. $3,11,19,...,9867$

យើងមាន $d=11-3=8$

តាង $n$ ជាចំនួនតួ ដែល $u_n=9867$

ដោយ $u_n=u_1+(n-1)d$

$=3+(n-1)\cdot 8$

$=8n-5$

យើងបាន $u_n=9867 \quad \Leftrightarrow 8n-5=9867$

$\Leftrightarrow 8n=9872$

$\Rightarrow n=1234$

ដូចនេះ ស៊ីតនព្វន្ត $3,11,19,...,9867$ មាន$1234$តួ

ខ. $2000,1985,1970,...,5$

យើងមាន $d=1985-2000=-15$

តាង $n$ ជាចំនួនតួ ដែល $u_n=5$

តែ $u_n=u_1+(n-1)d$

$=2000+(n-1)\cdot(-15)$

$=2015-15n$

យើងបាន $2015-15n=5$

$15n=2010$

$n=134$

ដូចនេះ ស៊ីតនព្វន្ត $2000,1985,1970,...,5$ មាន$134$ តួ

គ. $2222$ តួ

ឃ. $100$ តួ

លំហាត់គំរូទី៤ : ស៊ីតនព្វន្តមួយមានតួទីមួយស្មើ $-20$ និងផលសងរួមស្មើ $3$។

ក. គណនាតួទី១០នៃស៊ីតនេះ ។

ខ. សរសេររូបមន្តតួទី $n$ នៃស៊ីតនេះ

គ. តើតួទីប៉ុន្មាននៃស៊ីតនេះ ដែលមានតម្លៃស្មើនឹង $310$ ?

## ដំណោះស្រាយ

ក. គណនាតួទី$10$នៃស៊ីតនេះ

យើងមាន តួទីមួយ $u_1=-20$ និង ផលសងរួម $d=3$

យើងបាន តួទី១០: $u_{10}=u_1+(10-1)d$

$=-20+9\cdot 3$

$=7$

ដូចនេះ តួទី១០នៃស៊ីតនេះគឺ $\boxed{u_{10}=7}$

ខ. សរសេររូបមន្តតួទី $n$ នៃស៊ីតនេះ

$$u_n=u_1+(n-1)d$$

$$=-20+(n-1)\cdot 3$$

$$=3n-23$$

ដូចនេះ តួទី $n$ នៃស៊ីតនេះគឺ $\boxed{u_n=3n-23}$

គ. រកតួដែលមានតម្លៃស្មើនឹង $310$ ?

តាង $n$ ជាចំនួនតួ ដែល $u_n=310$

តែ $u_n=3n-23$

យើងបាន $3n-23=310$

$3n=333$

$n=111$

ដូចនេះ តួទី $111$ មានតម្លៃស្មើនឹង $310$

លំហាត់គំរូទី៥: រកតួទូទៅ$(u_n)$ និង តួទីដប់ $(u_{10})$ នៃស្វ៊ីតនព្វន្ត ខាងក្រោម:

ក. $1,7,13,...$ ខ. $6\,,\,\frac{11}{2}\,,\,5\,,\,...$

## ដំណោះស្រាយ

ក. $1,7,13,...$

យើងមាន $d=7-1=6$

យើងបាន $u_n=u_1+(n-1)d$

$=1+(n-1)\cdot 6$

$=6n-5$

ដូចនេះ តួទី $n$ គឺ $\boxed{u_n=6n-5}$

តួទី១០ : $u_{10}=6\cdot 10-5=55$

ខ. $6\,,\,\frac{11}{2}\,,\,5\,,\,...$

យើងមាន $d=\frac{11}{2}-6=-\frac{1}{2}$

យើងបាន $u_n=u_1+(n-1)d$

$=6+(n-1)\left(-\frac{1}{2}\right)$

$=\frac{12-n+1}{2}$

$=\frac{13-n}{2}$

ដូចនេះ $\boxed{u_n=\frac{13-n}{2}}$

តួទី១០ : $u_{10}=\frac{13-10}{2}=\frac{3}{2}$

លំហាត់គំរូទី៦ : គេឱ្យស៊ីត $(a_n)$ ដែលកំណត់ដោយទំនាក់ទំនង:

$$\begin{cases} a_1 = 7 \\ a_{n+1} = a_n + 3 \end{cases}, \ n \in \mathbb{N}$$ ។

ក. កំណត់ $a_n$ ដែលជាតួទី $n$ នៃស៊ីតនេះ ជាអនុគមន៍នៃ $n$ ។

ខ. គណនា $a_{13}$ , $a_{19}$ និង $a_{100}$ ។

គ. គណនា $p$ បើ $a_p = 154$ ។

## ដំណោះស្រាយ

ក. កំណត់ $a_n$ ដែលជាតួទី $n$ នៃស៊ីតនេះ ជាអនុគមន៍នៃ $n$

យើងមាន $a_{n+1} = a_n + 3 \Leftrightarrow a_{n+1} - a_n = 3$ (ជាចំនួនថេរ)

នោះ $(a_n)$ ជាស៊ីតនព្វន្តដែលមានផលសងរួម $d = 3$

យើងបាន

$$\begin{aligned} a_n &= a_1 + (n-1)d \\ &= 7 + (n-1)\cdot 3 \\ &= 3n + 4 \end{aligned}$$

ដូចនេះ $\boxed{a_n = 3n + 4}$

ខ. គណនា $a_{13}$ , $a_{19}$ និង $a_{100}$

យើងមាន $a_n = 3n + 4$

- $a_{13} = 3\cdot 13 + 4 = 43$
- $a_{19} = 3\cdot 19 + 4 = 61$
- $a_{100} = 3\cdot 100 + 4 = 604$

ដូចនេះ $\boxed{a_{13} = 43, a_{19} = 61, a_{100} = 604}$

គ. គណនា $p$

យើងមាន $a_n = 3n + 4$ នោះ $a_p = 3p + 4$

តែ $a_p = 154$

យើងបាន $3p+4=154$

$$3p=150$$

$$p=50$$

ដូចនេះ $\boxed{p=50}$

☞ **ចំណាំ: បើយើងដឹង $u_p$ ($p\in\mathbb{N}$) នោះយើងអាចគណនា $u_n$ បានតាម:**

$$\boxed{\mathbf{u_n=u_p+(n-p)d}}$$

## សម្រាយ

យើងមាន $u_n=u_1+(n-1)d$ (1)

នោះ $u_p=u_1+(p-1)d$ (2)

យកក $(1)-(2)$ យើងបាន $u_n-u_p=(n-p)d$

$$\Rightarrow u_n=u_p+(n-p)d$$

ដូចនេះ $\boxed{\mathbf{u_n=u_p+(n-p)d}}$ នោះ $\boxed{\mathbf{d=\dfrac{u_n-u_p}{n-p}}}$

លំហាត់គំរូទី៧ : គេឱ្យ $(u_n)$ ជាស្ទីតនព្វន្ត។ បើគេដឹងថា $u_{35}=9, u_{45}=17$ ។ គណនា $u_{40}$ ។

## ដំណោះស្រាយ

យើងមាន $u_{35}=9$ , $u_{45}=17$

ដោយ $(u_n)$ ជាស្ទីតនព្វន្តយើងបាន $u_{45}=u_{35}+(45-35)d$

$$\Rightarrow d=\frac{u_{45}-u_{35}}{45-35}=\frac{17-9}{10}=\frac{4}{5}$$

យើងបាន $u_{40}=u_{35}+(40-35)\cdot\dfrac{4}{5}$

$$=9+5\cdot\frac{4}{5}$$

$$=13$$

ដូចនេះ $\boxed{u_{40}=13}$

របៀបទី២: ដោយ $(u_n)$ ជាស្វ៊ីតនព្វន្តនោះ $u_{40}=\frac{u_{35}+u_{45}}{2}=\frac{9+17}{2}=13$

## លំហាត់អនុវត្តន៍

១. គេឱ្យ $(u_n)$ ជាស្វ៊ីតនព្វន្តដែលកំណត់ដោយ $u_8-u_5=30$ ។

គណនាផលសងរួម $d$ នៃស្វ៊ីតនេះ ។

២. រកតួទី $n$ នៃស្វ៊ីតនព្វន្តដែល $u_3=4$ និង $u_7=-24$ ។

៣. គេឱ្យស្វ៊ីតនព្វន្ត : $3\ ,\ 2\frac{1}{2}\ ,\ 2\ ,\ -6$ ។

ក. រក $u_1$ និង $d$

ខ. តើស្វ៊ីតនេះ មានប៉ុន្មានតួ ?

៤. គេឱ្យស្វ៊ីត $(u_n)$ ដែលកំណត់ដោយទំនាក់ទំនង: $\begin{cases}u_{n+1}=u_n+7\\ u_1=5\end{cases},n\in\mathbb{N}$ ។

ចូរគណនា $u_n$ ដែលជាតួទី $n$ នៃស្វ៊ីត។

## ៣. ផលបូកតួនៃស្វ៊ីតនព្វន្ត

### ក. ផលបូកស្មើចម្ងាយពីតួចុង

ផលបូកស្មើចម្ងាយពីតួចុង ស្មើនឹងផលបូកតួចុងទាំងពីរ ។

គេកំណត់សរសេរ $u_1+u_n=u_p+u_{n-p+1}$

ឬ បើ $m+n=p+k$ នោះ $u_m+u_n=u_p+u_k$ ។

**សម្គាល់ :**

- បើគេមានស្វ៊ីតនព្វន្ត $u_1 , u_2 , u_3 , u_4 , u_5 , u_6$

  នោះ $u_1 + u_6 = u_2 + u_5 = u_3 + u_4$
- បើ $u_1 , u_2 , u_3$ ជាស្វ៊ីតនព្វន្ត នោះ $2u_2 = u_1 + u_3$
- បើ $u_1 , u_2 , u_3 , u_4 , u_5$ ជាស្វ៊ីតនព្វន្ត

  នោះ $u_1 + u_5 = u_2 + u_4 = 2u_3$
- បើ $m + n = 2p$ ឬ $p = \dfrac{m+n}{2}$ នោះ $u_p = \dfrac{u_m + u_n}{2}$

លំហាត់គំរូទី១ : រកបីចំនួនជាស្វ៊ីតនព្វន្ត ដោយដឹងថាផលបូកតួនៃបីចំនួននេះស្មើនឹង 30 ហើយផលគុណវាស្មើនឹង 910 ។

## ដំណោះស្រាយ

រកបីចំនួននោះ

តាង $u_1 , u_2 , u_3$ ជាបីចំនួនជាស្វ៊ីតនព្វន្តនោះ

យើងបាន $\begin{cases} u_1 + u_2 + u_3 = 30 & (1) \\ u_1 \cdot u_2 \cdot u_3 = 910 & (2) \end{cases}$ (សន្មតយក $u_1 < u_2 < u_3$ )

តែ $u_1 , u_2 , u_3$ ជាស្វ៊ីតនព្វន្តនោះ $u_1 + u_3 = 2u_2 \quad (3)$

តាម $(1)$ និង $(3)$ យើងបាន $3u_2 = 30 \Rightarrow u_2 = 10$

យក $u_2 = 10$ ជំនួសក្នុង $(1)$ និង $(2)$ យើងបាន $\begin{cases} u_1 + u_3 = 20 \\ u_1 \cdot u_3 = 91 \end{cases}$

នោះ $u_1$ និង $u_3$ ជាឬសនៃសមីការ $U_2 - SU + P = 0$

$$U^2 - 20U + 91 = 0$$
$$\Delta' = 100 - 91 = 9 = 3^2$$
$$U = 10 - 3 = 7 \; , \; U' = 10 + 3 = 13$$

នោះ $u_1 = 7 \; , u_3 = 13$

ដូចនេះ បីចំនួននោះ គឺ $\boxed{7 \; , \; 10 \; , 13}$

លំហាត់គំរូទី២ : គេឱ្យ $(u_n)$ ជាស៊ីតនព្វន្តដែល $u_7 = 25$ និង $u_{103} = 313$ ។ គណនា $u_{55}$ ។

### ដំណោះស្រាយ

គណនា $u_{55}$

ដោយ $55 = \frac{7+103}{2}$ នោះ $u_{55} = \frac{u_7 + u_{103}}{2} = \frac{25+313}{2} = 169$

ដូចនេះ $\boxed{u_{55} = 169}$

- **ករណីពិសេស :**

| |
|---|
| បីចំនួន $a, b, c$ ជាបីតួតគ្នានៃស៊ីតនព្វន្តកាលណា $2b = a + c$ ឬ $b = \frac{a+c}{2}$ $b$ ហៅថា មធ្យមនព្វន្ត នៃ $a$ និង $c$ ។ |

**ដូចនេះ ដើម្បីបង្ហាញថា បីចំនួនតគ្នា a , b , c ជាស៊ីតនព្វន្ត យើងត្រូវបង្ហាញ $2b = a + c$ ឬ $b = \frac{a+c}{2}$**

លំហាត់គំរូទី៣ : បង្ហាញថា $\frac{a}{a-1}, \frac{3a-2}{a^2-1}, \frac{4-a}{a+1}$ ជាបីតួតគ្នានៃស៊ីនព្វន្ត។

### ដំណោះស្រាយ

យើងមាន $\frac{a}{a-1} + \frac{4-a}{a+1} = \frac{a(a+1)+(4-a)(a-1)}{(a-1)(a+1)}$

$$= \frac{a^2 + a + 4a - 4 - a^2 + a}{a^2 - 1}$$

$$= \frac{6a-4}{a^2-1} = 2\left(\frac{3a-2}{a^2-1}\right)$$

ដោយ $2\left(\frac{3a-2}{a^2-1}\right) = \frac{a}{a-1} + \frac{4-a}{a+1}$

ដូចនេះ $\frac{a}{a-1}, \frac{3a-2}{a^2-1}, \frac{4-a}{a+1}$ ជាបីតួតគ្នានៃស៊ីនព្វន្ត

# លំហាត់អនុវត្តន៍

១. រកបីចំនួនជាស្វ៊ីតនព្វន្ត ដោយដឹងថាផលបូកនៃបីចំនួននេះស្មើនឹង $30$ និងផលគុណវា ស្មើនឹង $910$។

២. គេឱ្យ $(u_n)$ ជាស្វ៊ីតនព្វន្តដែល $u_{15}=71, u_{2015}=8071$ ។ គណនា $u_{1015}$ ។

៣. . គេឱ្យ $(u_n)$ ជាស្វ៊ីតនព្វន្តដែលមាន $u_7=25$ និង $u_{103}=313$ ។ គណនា $u_{55}$ ។

៤. គេឱ្យ $(u_n)$ ជាស្វ៊ីតនព្វន្តដែលមាន $u_{35}=9$ និង $u_{45}=17$ ។ គណនា $u_{40}$ ។

៥. រកបីតួបន្តបន្ទាប់គ្នា នៃស្វ៊ីតនព្វន្តមួយ ដោយដឹងថាផលបូករបស់វាស្មើនឹង $3$ និង ផលគុណរបស់វាស្មើនឹង $-15$ ។

៦. បង្ហាញថា ចំនួនខាងក្រោមជាស្វ៊ីតនព្វន្ត

ក. $\frac{1}{x+1}, \frac{x}{x^2-1}, \frac{1}{x-1}$

ខ. $(a^2+b^2)^2 , a^4+b^4 , (a^2-b^2)^2$

គ. $\frac{4}{x-1}, \frac{6x}{x^3-1}, \frac{4-4x}{x^2+x+1}$

ឃ. $(a^2-2ab-b)^2 , (a^2+b^2)^2, (a^2+ab-b^2)^2$

៧. បើ $\frac{1}{a+b}, \frac{1}{a+c}, \frac{1}{b+c}$ ជាស្វ៊ីតនព្វន្ត បង្ហាញថា $a^2 , b^2 , c^2$ ជាស្វ៊ីតនព្វន្ត ។

៨. បើ $a,b,c$ ជាស្វ៊ីតនព្វន្ត ។ បង្ហាញថា $a^2-bc , b^2-ac , c^2-ab$ ជាស្វ៊ីតនព្វន្ត ។

៩. បើ $a , b , c$ ជាស្វ៊ីតនព្វន្ត បង្ហាញថា $a^2+ab+b^2 , a^2+ac+c^2$ និង $b^2+bc+c^2$ ជាស្វ៊ីតនព្វន្ត ។

## ២. ផលបូក n តួដំបូងនៃស៊ីតនព្វន្ត

ផលបូក $n$ តួដំបូងនៃស៊ីតនព្វន្តដែលមាន $u_1$ ជាតួទី១ និង $u_n$ ជាតួទី $n$ គឺ $\mathbf{S_n = \frac{n}{2}(u_1 + u_n)}$ ឬ $\mathbf{S_n = \frac{n}{2}[2u_1 + (n-1)d]}$ ។

### សម្រាយបញ្ជាក់

តាង $S_n$ ជាផលបូក $n$ តួដំបូងនៃស៊ីតនព្វន្ត

យើងបាន $S_n = u_1 + u_2 + u_3 + ... + u_{n-2} + u_{n-1} + u_n$ (1)

ឬ $S_n = u_n + u_{n-1} + u_{n-2} + ... + u_3 + u_2 + u_1$ (2)

$(1)+(2)$ យើងបាន:

$$2S_n = (u_1 + u_n) + (u_2 + u_{n-1}) + ... + (u_{n-1} + u_2) + (u_n + u_1)$$

តែ $u_1 + u_n = u_2 + u_{n-1} = ... = u_{n-1} + u_2 = u_n + u_1$

(តាមផលបូកស្មួចម្ងាយពីតួចុង)

យើងបាន:

$$2S_n = (u_1 + u_n) + (u_1 + u_n) + ... + (u_1 + u_n) + (u_1 + u_n) = n(u_1 + u_n)$$

$\Rightarrow S_n = \frac{n}{2}(u_1 + u_n)$ ហើយ ដោយ $u_n = u_1 + (n-1)d$

ដូចនេះ $\boxed{\mathbf{S_n = \frac{n}{2}(u_1 + u_n) = \frac{n}{2}[2u_1 + (n-1)d]}}$

**Note :** $S_1 = u_1$ , $S_2 = u_1 + u_2$ , $S_3 = u_1 + u_2 + u_3$

$S_{n-1} = u_1 + u_2 + ... + u_{n-1}$ ហើយ $S_n = u_1 + u_2 + ... + u_{n-1} + u_n$

នោះ $S_n - S_{n-1} = u_n$

ដូចនេះ $\boxed{\mathbf{u_n = S_n - S_{n-1}}}$

លំហាត់គំរូទី១: គណនាផលបូក 12 តួដំបូងនៃស្វ៊ីតនព្វន្ត $5,12,19,26,\dots$

## ដំណោះស្រាយ

គណនាផលបូក 12 តួដំបូងនៃស្វ៊ីតនព្វន្ត $5,12,19,26,\dots$

យើងមាន $d=12-5=7$

ហើយ $u_1=5\Rightarrow u_{12}=u_1+(12-1)d=5+11\cdot 7=82$

តាមរូបមន្ត $S_n=\frac{n}{2}\left(u_1+u_n\right)$

យើងបាន
$$S_{12}=\frac{12}{2}\left(u_1+u_{12}\right)=\frac{12}{2}\left(5+82\right)=522$$

ដូចនេះ $\boxed{S_{12}=522}$

**របៀបម្យ៉ាងទៀត**

យើងមាន $d=12-5=7$

តាមរូបមន្ត $S_n=\frac{n}{2}\left[2u_1+(n-1)d\right]$

យើងបាន
$$S_{12}=\frac{12}{2}\left[2u_1+(12-1)d\right]=6\left(2\cdot 5+11\cdot 7\right)=6(10+77)=552$$

លំហាត់គំរូទី២: គណនាផលបូក $(-6)+(-1)+4+9+\cdots+64$

## ដំណោះស្រាយ

តាង $S_n=(-6)+(-1)+4+9+\cdots+64$

រកចំនួនតួនៃផលបូលតួស៊ីតនេះ (ស៊េរី)

តាង $n$ ជាចំនួនតួ ដែល $u_n = 64$

យើងមាន $d = (-1) - (-6) = 5$

នោះ $u_n = u_1 + (n-1)d$

$= -6 + (n-1)\cdot 5$

$= 5n - 11$

យើងបាន $5n - 11 = 64$

$5n = 75$

$n = 15$

តាមរូបមន្ត $S_n = \frac{n}{2}\left(u_1 + u_n\right)$

យើងបាន $S_{15} = \frac{15}{2}\left(u_1 + u_{15}\right)$

$= \frac{15}{2}\left(-6 + 64\right)$

$= 435$

ដូចនេះ $\boxed{(-6) + (-1) + 4 + 9 + \cdots + 64 = 435}$

លំហាត់គំរូទី៣ : គណនា $1 + 3 + 5 + 7 + \cdots + (2n-1)$

## ដំណោះស្រាយ

តាង $S_n = 1 + 3 + 5 + 7 + \cdots + (2n-1)$

ដោយស៊ីត $1, 3, 5, 7, \ldots, (2n-1)$ ជាស៊ីតនព្វន្តដែលមាន $d = 3 - 1 = 2$

យើងបាន $S_n = \frac{n}{2}\left(u_1 + u_n\right)$

$= \frac{n}{2}\left[1 + (2n-1)\right]$

$= n^2$

ដូចនេះ $\boxed{1 + 3 + 5 + 7 + \cdots + (2n-1) = n^2}$

លំហាត់គំរូទី៤ : គណនាផលបូក 25 តួដំបូងនៃស្វ៊ីតនព្វន្ត $2,9,16,25,\ldots$

**ដំណោះស្រាយ**

យើងមាន $d=9-2-7$ ហើយ $u_1=2$

យើងបាន $S_{25}=\frac{25}{2}\left[2u_1+(25-1)d\right]$

$=\frac{25}{2}\left(2\cdot 2+24\cdot 7\right)$

$=2150$

ដូចនេះ $\boxed{S_{25}=2150}$

លំហាត់គំរូទី៥ : គេមានការងាររដូវក្តៅ២ សម្រាប់រយៈពេល ៣ខែ ឬ ១២សប្តាហ៏។ ការងារ $A$ ទទួលបានប្រាក់បៀវត្ស 325000 រៀលក្នុងមួយខែ ហើយដំឡើង 100000 រៀល រៀងរាល់ខែ ។ ការងារ $B$ ទទួលបានប្រាក់បៀវត្ស 80000 រៀលក្នុងមួយសប្តាហ៏ ហើយដំឡើង 3000 រៀល រៀងរាល់សប្តាហ៏។

តើគេគួរជ្រើសរើសយកការងារណាប្រសើរជាង ?

**ដំណោះស្រាយ**

- ចំពោះការងារ $A$ ប្រាក់បៀវត្សគឺ

$S_A=325000+(325000+100000)+(325000+10000+10000)$

$=325000+425000+525000$

$=1275000$ រៀល

- ចំពោះការងារ $B$ ប្រាក់បៀវត្សគឺ $80000,(80000+3000)$, $(80000+3000+3000),\ldots$ ជាស្វ៊ីតនព្វន្តដែលមាន $u_1=80000$ និងផលសងរួម $d=3000$

នោះប្រាក់បៀវត្សនៅ១២ សប្តាហ៍គឺ $S_B = \frac{12}{2}\left[2u_1 + (12-1)d\right]$

$= 6\left(2\cdot 80000 + 11\cdot 3000\right)$

$= 1158000$ រៀល

ដោយ $S_A = 1275000$ រៀល $> S_B = 1158000$ រៀល

ដូចនេះ គេគួរជ្រើសរើសការងារ $A$ ប្រសើរជាង

លំហាត់គំរូទី៦ : គេមានស្វ៊ីតនព្វន្ត $51, 47, 43, \ldots$ ។ កំណត់ចំនួនតួ ( $n$ ) ដើម្បីឱ្យផលបូក $n$ តួដំបូង( $S_n$ ) មានតម្លៃអតិបរមា និង កំណត់ $S_n$ ។

## ដំណោះស្រាយ

កំណត់ចំនួនតួ

តាង $u_n$ ជាតួទូទៅនៃស្វ៊ីតនព្វន្តនេះ

ដោយ $d = 47 - 51 = -4$ ហើយ $u_1 = 51$

យើងបាន $u_n = u_1 + (n-1)d$

$= 51 + (n-1)(-4)$

$u_n = 55 - 4n$

ផលបូក $n$ តួដំបូងមានតម្លៃអតិបរមា កាលណា $u_n \geq 0$ ចំពោះគ្រប់ $n \in \mathbb{N}$

យើងបាន $55 - 4n \geq 0$

$\Rightarrow n \leq \frac{55}{4} = 13.75 \ , n \in \mathbb{N}$

នោះយើងទាញបាន $S_n$ មានតម្លៃអតិបរមា កាលណា $n = 13$

គណនា $S_{13}$

យើងមាន $u_n = 55 - 4n \Rightarrow u_{13} = 55 - 4\cdot 13 = 3$

យើងបាន $S_{13}=\frac{13}{2}(u_1+u_{13})$

$=\frac{13}{2}(51+3)$

$=351$

ដូចនេះ ផលបូក $n$ តួដំបូង( $S_n$ ) មានតម្លៃអតិបរមាកាលណា $n=13$

ហើយ $S_{13}=351$

លំហាត់គំរូទី៧ : កំណត់តម្លៃ $n$ ដើម្បីឱ្យផលបូក $n$ តួដំបូង ( $S_n$ ) នៃស៊ីតនព្វន្ត: $-28,-25,-22,\ldots$ មានតម្លៃអប្បបរមា រួចគណនាតម្លៃអប្បបរមានោះ។

**ដំណោះស្រាយ**

តាង $u_n$ ជាតួនៃស៊ីតនព្វន្ត

ដោយ $d=(-25)-(-28)=3$ ហើយ $u_1=-28$

យើងបាន $u_n=u_1+(n-1)d$

$=-28+(n-1)\cdot 3$

$=3n-31$

$S_n$ មានតម្លៃអប្បបរមាកាលណា $u_n\le 0$

យើងបាន $3n-31\le 0$

$\Rightarrow n\le\frac{31}{3}=10.33$

នោះ យើងទាញបាន $n=13$

$S_{10}=\frac{10}{2}\left[2u_1+(10-1)d\right]$

$=5\left[2\cdot(-28)+9\cdot 3\right]$

$=-145$

ដូចនេះ $\boxed{n=10\ ,\ S_{10}=-145}$

# លំហាត់អនុវត្តន៍

១. គេឱ្យស៊ីតនព្វន្ត $5,12,19,26,...$

ក. គណនា តួទី $16$ ។

ខ. គណនាផលបូក $16$ តួដំបូងនៃស៊ីតនេះ ។

២. គណនាផលបូក $7$ តួដំបូងនៃស៊ីតនព្វន្ត $12,9,6,\dots$ ។

៣. គណនាផលបូកនៃស៊ីតននព្វន្តខាងក្រោម៖

ក. $2+6+10+14+\cdots+122$

ខ. $100+95+90+85+\cdots+(-20)$

គ. $4+10+16+22+\cdots+334$

៤. គណនាផលបូក $20$ តួដំបូងនៃស៊ីតនព្វន្ត $7,3,-1,-5,...$

៥. កំណត់ចំនួនតួនៃស៊ីតនព្វន្តខាងក្រោម រួចគណនាផលបូកតួនៃស៊ីតនេះ

ក. $5,8,11,14,\dots,62$

ខ. $1,6,11,16,\dots,506$

គ. $-193,-189,-185,\dots,-17$

ឃ. $2\frac{1}{4},2\frac{17}{20},3\frac{9}{20},\dots,20\frac{1}{4},20\frac{17}{20}$

៦. កំណត់តួទី១ និងផលសងរួមនៃស៊ីតនព្វន្តមួយ ដោយដឹងថាផលបូក $n$ តួដំបូងស្មើនឹង $\frac{n^2}{2}$ ។

៧. គណនាផលបូក $10$ តួដំបូងនៃស៊ីតនព្វន្ត $17,14,11,8,5,...$ រួចកំណត់ចំនួនតួដើម្បីឱ្យផលបូកនៃស៊ីតនេះមានតម្លៃអតិបរមា (ធំបំផុត) ។ គណនាតម្លៃអតិបរមានៃ $S_n$ ។

៨. គេមានស៊ីតនពន្ត $85,73,61,49,...$ ។ កំណត់ចំនួនតួ $(n)$ ដើម្បីឱ្យផលបូក $n$ តួដំបូងមានតម្លៃអតិបរមា រួចគណនាតម្លៃអតិបរមានៃ $S_n$ ។

# លំហាត់

១. សរសេររូបមន្តតួទី $n$ រួចគណនាផលបូក $20$ តួដំបូងនៃស្វ៊ីតនព្វន្ត ខាងក្រោម :

ក. $1, 5, 9, \ldots$

ខ. $50, 48, 46, \ldots$

គ. $-7, -3, 1, \ldots$

២. គេមានស្វ៊ីតនព្វន្ត $-8, -3, 2, 7, \ldots$ ។

ក. គណនា $u_{17}$ និង $u_{43}$ ។

ខ. តើតួទីប៉ុន្មាននៃស្វ៊ីតដែលស្មើនឹង $322$?

៣. កំណត់ចំនួនតួ រួច គណនាផលបូកតួនៃស្វ៊ីតនព្វន្តខាងក្រោម :

ក. $18, 13, 8, \ldots, -102$

ខ. $-9, -4, 1, \ldots 171$

គ. $105, 110, 115, \ldots 995$

ឃ. $1, 6, 11\ 16, \ldots, 506$

៤. គេឱ្យ $(u_n)$ ជាស្វ៊ីតនព្វន្ត បើគេដឹងថា

ក. $u_7 = \frac{7}{2}$ និង $u_{13} = \frac{13}{2}$ ។ ចូរគណនា $u_2$ ។

ខ. $u_2 = -12$ និង $S_{12} = 18$ ។ គណនា $u_1$ , $d$ និង $u_6$ ។

៥. គេឱ្យប្រាំចំនួនជាស្វ៊ីតនព្វន្ត ។ គណនាចំនួនទាំងនោះ បើគេដឹងថា ផលបូវាស្មើនឹង $125$ ហើយផលបូកពីរតួដំបូងស្មើនឹង $38$ ។

៦. ផលបូក $9$ តួដំបូងនៃស្វ៊ីតនព្វន្តស្មើនឹង $162$ ហើយផលបូក $12$ តួដំបូង នៃស្វ៊ីតនព្វន្តស្មើនឹង $288$ ។ គណនាផលបូក $30$ តួដំបូងនៃស្វ៊ីតនព្វន្ត ។

៧. រកបីចំនួនតគ្នានៃស្វ៊ីតនព្វន្តមួយដោយដឹងថាផលបូកនៃបីចំនួននេះស្មើ នឹង $36$ និង ផលគុណវាស្មើនឹង $1428$ ។

៨. គេឱ្យស្វ៊ីតនព្វន្តមួយដែលមានតួទីបីស្មើ 18 និង តួទី17 ស្មើ 30 ។
គណនាផលបូក 33តួដំបូងនៃស្វ៊ីតនេះ ។

៩. គេឱ្យស្វ៊ីតនព្វន្តមួយមាន $u_4 = 15$ និង $S_5 = 55$ ។ គណនា $u_1$ និង $d$ ។

១០. ស្វ៊ីតនព្វន្តមួយមាន $u_{13} = 6u_2$ និង $S_{15} = 615$ ។ គណនា $u_1$ និង $d$ ។

១១. ស្វ៊ីតនព្វន្តមួយមានតួទី៣ស្មើនឹង $-20$ និង តួទី១១ស្មើនឹង 20 ។
គណនាផលបូក 13តួដំបូងនៃស្វ៊ីតនេះ ។

១២. គេឱ្យបីចំនួនបង្កើតបានជាស្វ៊ីតនព្វន្តមួយ ។ ផលបូកនៃចំនួនទាំងបីនេះ ស្មើនឹង 18 ហើយផលបូកនៃការេរបស់វាស្មើនឹង 206 ។
រកចំនួនទាំងបីនោះ ។

១៣.ផលបូកបីតួនៃស្វ៊ីតនព្វន្តស្មើ33 ហើយផលគុណរបស់វាស្មើ 1287 ។
រកចំនួនទាំងបីនោះ ។

១៤. តើគេអាចយកប៉ុន្មានតួនៃស្វ៊ីតនព្វន្តមួយដែលមានផលសងរួម $d = 3$
ហើយតួទីមួយ $u_1 = 7$ និង ផលបូកតួស្មើ 205 ?

១៥. គេឱ្យស្វ៊ីតនព្វន្ត $5, 8, 11, 14, \ldots$ ។ តើគេត្រូវបូកប៉ុន្មានតួនៃស្វ៊ីតនេះ
ដើម្បីឱ្យផលបូកមានតម្លៃស្មើនឹង 98 ។

១៦. គេឱ្យ $(u_n)$ ជាស្វ៊ីតនព្វន្តដែលមានតួទី $u_1 = 1$ និងផលសងរួម $d$ ។
គណនា $d$ ដើម្បីឱ្យផលបូក 100តួដំបូងស្មើនឹង 1 ។ តើមានតួណា
ស្មើនឹងសូន្យ ឬទេ ? បើមានតើនៅតួទីប៉ុន្មាន ?

១៧. នៅក្នុងស្វ៊ីតនព្វន្តមួយ គេឱ្យផលបូក $2n$ តួដំបូង ស្មើនឹងពាក់កណ្តាល
នៃផលបូក $3n$ តួដំបូង ។ ប្រសិនបើតួទី១ ស្មើនឹង 12 និង ផលសងរួម
ស្មើនឹង 3 ចូរគណនាតម្លៃនៃ $n$ ។

១៨. គេឱ្យស្វ៊ីតនព្វន្ត $(u_n)$ មាន $u_3 = -15$ និង $u_{14} = 18$ ។
គណនាផលបូក 20 តួដំបូងនៃស្វ៊ីតនេះ ។

១៩. កំណត់តម្លៃ $x$ ដើម្បីឱ្យបីចំនួន $10-3x$ , $2x^2+3$ , $7-4x$ បង្កើតបានជាស៊ីតនព្វន្ត ។

២០. គេឱ្យ $(u_n)$ ជាស៊ីតនព្វន្តដែល $u_1+u_4+u_7+u_{10}+u_{13}+u_{16}=2013$ ។
ចូរគណនា $u_1+u_6+u_{11}+u_{16}$ ។

២១. គណនាតួទី $n$ និង ផលបូក $n$ តួដំបូងនៃស៊ីត $1,\frac{n-1}{n},\frac{n-2}{n},\frac{n-3}{n},...$

២២. បង្ហាញថាស៊ីត $(u_n)$ ដែល $u_n=\frac{2n+3}{5}$ ជាស៊ីតនព្វន្តកើន រួចគណនា $S_{10}$ ។

២៣. គេមានស៊ីតនព្វន្ត $2\,,7\,,12\,,...$ និងស៊ីតនព្វន្ត $2\,,5\,,8\,,...$ ។
តើក្នុងចំណោម ១២១ តួដំបូងនៃស៊ីតទាំងពីរនេះ មានប៉ុន្មានតួដែលមានតម្លៃស្មើៗគ្នា?

២៤. គេមានស៊ីតនព្វន្ត $1\,,3\,,5\,,...$ និងស៊ីតនព្វន្ត $1\,,5\,,9\,,...$ ។
តើក្នុងចំណោម ១៥០តួដំបូងនៃស៊ីតទាំងពីរនេះ មានប៉ុន្មានតួដែលមានតម្លៃស្មើៗគ្នា?

២៥. គេមានស៊ីតនព្វន្ត $1,4,7,...$ និងស៊ីតនព្វន្ត $1,5,11,...$ ។
តើក្នុងចំណោម ២០១៣តួដំបូងនៃស៊ីតទាំងពីរនេះ មានប៉ុន្មានតួដែលមានតម្លៃស្មើៗគ្នា ?

២៦. ស៊ីតនព្វន្តមួយមាន តួទី១ $u_1=-23$ និងផលសងរួម $d=2.5$ ។
កំណត់តម្លៃអប្បបរមានៃ $n$ ដើម្បីឱ្យ $S_n>0$ ។

២៧. ស៊ីតនព្វន្តមួយមាន តួទី១ $u_1=-61$ និងផលសងរួម $d=4$ ។
កំណត់តម្លៃអប្បបរមានៃ $n$ ដើម្បីឱ្យ $S_n>0$ ។

២៨. ស៊ីតនព្វន្តមួយមានតួទី១ $u_1=10$ និងផលសងរួម $d=0.25$ ។
រកចំនួនតួតិចបំផុតដែលផលបូកតួនៃស៊ីតនេះមានតម្លៃលើសពី $300$ ។

២៩. ស៊ីតនព្វន្តមួយមានតួទី១ $u_1=-5$ និងផលសងរួម $d=1.5$ ។
រកចំនួនតួច្រើនបំផុតដែលផលបូកតួនៃស៊ីតនេះមានតម្លៃមិនលើសពី $450$ ។

# មេរៀនទី ៣ ស៊ីតធរណីមាត្រ

## ១. និយមន័យ

ស៊ីតធរណីមាត្រ គឺជាស៊ីតនៃចំនួនពិត ដែលតួនីមួយៗ(ក្រៅពីតួទី១) ស្មើនឹងតួមុនបន្ទាប់ គុណនឹងចំនួនថេរ $q$ ដែល $q \neq 0$ ។ ចំនួនថេរ $q$ ហៅថាផលធៀបរួមនៃស៊ីតធរណីមាត្រ ។

➢ Note : ឯកសារខ្លះតាង ផលធៀបរួមនៃស៊ីតធរណីមាត្រដោយ $r$ (ratio)

➢ ផលធៀបរួបនៃស៊ីតធរណីមាត្រ $(q \neq 0$ ឬ $r \neq 0)$កំណត់ដោយៈ

$$\mathbf{q = \frac{u_2}{u_1} = \frac{u_3}{u_2} = \frac{u_4}{u_3} = \dots = \frac{u_n}{u_{n-1}}}$$

ឧទាហរណ៍ : ស៊ីត$(a_n): 2, 4, 8, 16, 32, \dots$ គឺជាស៊ីតធរណីមាត្រដែលមាន ផលធៀបរួម $q = \frac{4}{2} = \frac{8}{4} = \frac{16}{8} = 2$

លំហាត់គំរូ : រកផលធៀបរួមនៃស៊ីតធរណីមាត្រដែលមានតួទី12 ស្មើនឹង 531441 និង តួទី13 ស្មើនឹង1594323 ។

**ដំណោះស្រាយ**

យើងមាន $u_{12} = 531441$ និង $u_{13} = 1594323$

យើងបាន $q = \frac{1594323}{531441} = 3$

ដូចនេះ ផលធៀបរួមនៃស៊ីតនេះគឺ $q = 3$

## ២. តួទី n នៃស្វ៊ីតធរណីមាត្រ

> បើ $(u_n)$ ជាស្វ៊ីតធរណីមាត្រដែលមានតួទី១ $u_1$ និងផលធៀបរួម $q$ នោះតួទី $n$ នៃស្វ៊ីតនេះ កំណត់ដោយ $u_n = u_1 \times q^{n-1}$ ។

### សម្រាយ(តាមលំនាំគំរូ)

យើងមាន $q = \dfrac{u_n}{u_{n-1}}$ ឬ $u_n = u_{n-1} \cdot q$ $\quad (n \geq 2\ , n \in \mathbb{N})$

យើងបាន $u_2 = u_1 \cdot q = u_1 \cdot q^{2-1}$

$u_3 = u_2 \cdot q = (u_1 \cdot q) \cdot q = u_1 \cdot q^2 = u_1 \cdot q^{3-1}$

$u_4 = u_3 \cdot q = (u_1 \cdot q^2) \cdot q = u_1 \cdot q^3 u_1 \cdot q^{4-1}$

..............................................

..............................................

$\Rightarrow u_n = u_1 \cdot q^{n-1}$

ដូចនេះ $u_n = u_1 \cdot q^{n-1}$

### សម្រាយតាមអនុមាណរួមគណិតវិទ្យា

ស្រាយថា $u_n = u_1 \cdot q^{n-1}$ $\quad (*)$

យើងមាន $u_n = u_{n-1} \cdot q$

បើ $n = 2$ នោះ $u_2 = u_1 . q = u_1 \cdot q^{n-1}$ ពិត

ឧបមាថា (8) ពិតដល់ $n = k$ នោះ $u_k = u_1 . q^{n-1}$

យើងនឹងស្រាយថា $(*)$ ពិតដល់ $n = k+1$

$u_{k+1} = u_k \cdot q = u_1 \cdot q^{n-1} \cdot q = u_1 \cdot q^{(n+1)-1}$ ពិត

ដូចនេះ $u_n = u_1 \cdot q^{n-1}$

លំហាត់គំរូទី១ : គណនាតួទី $n$ នៃស្វ៊ីតធរណីមាត្រ $3, 12, 48, 192, \ldots$

**ដំណោះស្រាយ**

យើងមាន ស្វ៊ីតធរណីមាត្រ $3, 12, 48, 192, \ldots$

$$q = \frac{12}{3} = 4$$

យើងបាន $u_n = u_1 \cdot q^{n-1} = 3 \cdot 4^{n-1}$

លំហាត់គំរូទី២ : គេមានស្វ៊ីតធរណីមាត្រ $6, 18, 54, \ldots$ ។

ក. គណនាតួទី $8$ ។

ខ. សរសេរ រូបមន្តតួទី $n$ នៃស្វ៊ីតនេះ ។

គ. តើចំនួន $118098$ ជាតួទីប៉ុន្មាននៃស្វ៊ីត។

**ដំណោះស្រាយ**

ក. គណនា $u_8$

យើងមាន $u_1 = 6$ ហើយ $q = \frac{18}{6} = 3$

យើងបាន
$$u_8 = u_1 \cdot q^{8-1} = 6 \cdot 3^7 = 13122$$

ដូចនេះ តួទី $8$ គឺ $u_8 = 13122$

ខ. សរសេរ រូបមន្តតួទី $n$ នៃស្វ៊ីតនេះ

$$u_n = u_1 \cdot q^{n-1} = 6 \cdot 3^{n-1} = 2 \cdot 3^n$$

ដូចនេះ $\boxed{u_n = 2 \cdot 3^n}$

គ. រកតួដែលមានតម្លៃស្មើនឹង 118098

តាង $n$ ជាចំនួនតួដែល $u_n = 118098$

តែ $u_n = 2\cdot 3^n$

យើងបាន $2\cdot 3^n = 118098$

$3^n = 59049 = 3^{10}$

$\Rightarrow n = 10$

ដូចនេះ ចំនួន 118098 នៅតួទី 10

លំហាត់គំរូទី៣ : កំណត់ចំនួនតួនៃស៊ីតធរណីមាត្រខាងក្រោម ៖

ក. $1, 2, 4, 8, \ldots, 8192$

ខ. $20, 10, 5, \frac{5}{2}, \ldots, \frac{5}{256}$

**ដំណោះស្រាយ**

ក. $1, 2, 4, 8, \ldots, 8192$

យើងមាន $q = \frac{2}{1} = 2$

តាង $n$ ជាចំនួនតួ ដែល $u_n = 8192$

តែ $u_n = u_1 \cdot q^{n-1}$

$= 1\cdot 2^{n-1} = 2^{n-1}$

យើងបាន $2^{n-1} = 8192 = 2^{13}$

$n - 1 = 13$

$\Rightarrow n = 14$

ដូចនេះ ស៊ីតធរណីមាត្រ $1, 2, 4, 8, \ldots, 8192$ មាន 14 តួ

ខ. $20, 10, 5, \frac{5}{2}, \ldots, \frac{5}{256}$

យើងមាន $q = \frac{10}{20} = \frac{1}{2}$

តាង $n$ ជាចំនួនតួដែល $u_n=\frac{5}{256}$

តែ $u_n=u_1\cdot q^{n-1}$

$$=20\cdot\left(\frac{1}{2}\right)^{n-1}$$

$$=\frac{20}{2^{n-1}}$$

យើងបាន $\frac{20}{2^{n-1}}=\frac{5}{256}$

$$20\cdot256=5\cdot2^{n-1}$$

$$2^{n-1}=\frac{20\cdot256}{5}=1024=2^{10}$$

$$n-1=10$$

$$\Rightarrow n=11$$

ដូចនេះ ស្វ៊ីតធរណីមាត្រ $20\,,10\,,5\,,\frac{5}{2}\,,\ldots,\frac{5}{256}$ មាន 11 តួ

លំហាត់គំរូទី៤ : គេឱ្យស្វ៊ីត$(u_n)$កំណត់ដោយ $\begin{cases}u_1=5\\u_{n+1}=2u_n\,,n\in\mathbb{N}\end{cases}$ ។

ក. កំណត់ $u_n$ ដែលជាតួទី$n$ នៃស្វ៊ីតនេះ ជាអនុគមន៍នៃ$n$ ។

ខ. គណនា $u_{11}$ ។

គ. គណនា $p$ បើ $u_p=20480$ ។

## ដំណោះស្រាយ

ក. កំណត់ $u_n$ ដែលជាតួទី$n$ នៃស្វ៊ីតនេះ ជាអនុគមន៍នៃ$n$

យើងមាន $u_{n+1}=2u_n\Leftrightarrow\frac{u_{n+1}}{u_n}=2$ (ជាចំនួនថេរ)

នោះ $(u_n)$ ជាស្វ៊ីតឱធរណីមាត្រដែលមានផលធៀបរួម $q=2$

យើងបាន $u_n=u_1\cdot q^{n-1}=5\cdot2^{n-1}$

ដូចនេះ $u_n = 5\cdot 2^{n-1}$

ខ. គណនា $u_{11}$

យើងងមាន $u_n = 5\cdot 2^{n-1}$

$$\Rightarrow u_{11} = 5\cdot 2^{11-1} = 5\cdot 1024 = 5120$$

ដូចនេះ $u_{11} = 5120$

គ. គណនា $p$

យើងមាន $u_n = 5\cdot 2^{n-1} \Rightarrow u_p = 5\cdot 2^{p-1}$

តែ $u_p = 20480$

យើងបាន $5\cdot 2^{p-1} = 20480$

$$2^{p-1} = 4096 = 2^{12}$$

$$p-1 = 12$$

$$\Rightarrow p = 13$$

ដូចនេះ $p = 13$

☞ **ចំណាំ**

❶ ដើម្បីបង្ហាញថា $(u_n)$ ជាស្វ៊ីតធរណីមាត្រ យើងត្រូវបង្ហាញថា

$\dfrac{u_{n+1}}{u_n} = C$ ដែល $C$ ជាចំនួនថេរ

❷ បើយើងដឹង $u_p$ $(p \in \mathbb{N})$ នោះយើងអាចគណនា $u_n$ បានគឺ

$$u_n = u_p \times q^{n-p}$$

**ស្រាយបញ្ជាក់ថា** $u_n = u_p \cdot q^{n-p}$

យើងមាន $u_n = u_1 \cdot q^{n-1}$ (1)

នោះ $u_p = u_1 \cdot q^{p-1}$ (2)

ធ្វើផលធៀប (1) និង (2) យើងបាន $\frac{u_n}{u_p} = \frac{u_1 \cdot q^{n-1}}{u_1 \cdot q^{p-1}} = q^{n-p}$

$$\Rightarrow u_n = u_p \cdot q^{n-p}$$

ដូចនេះ $\boxed{u_n = u_p \cdot q^{n-p}}$

លំហាត់គំរូទី៥ : គេឱ្យ $(u_n)$ ជាស៊ីតមួយកំណត់ដោយ $u_3 = 27$ និង $u_{n+1} = 3u_n$ ដែល $n \in \mathbb{N}$ ។

ក. បង្ហាញថា $(u_n)$ ជាស៊ីតធរណីមាត្រ។

ខ. គណនា $u_n$ ជាអនុគមន៍នៃ $n$ ។

**ដំណោះស្រាយ**

ក. បង្ហាញថា $(u_n)$ ជាស៊ីតធរណីមាត្រ

យើងមាន $u_{n+1} = 3u_n \Leftrightarrow \frac{u_{n+1}}{u_n} = 3$ ជាចំនួនថេរ

ដូចនេះ $(u_n)$ ជាស៊ីតធរណីមាត្រដែលមានផលធៀបរួម $q = 3$

ខ. គណនា $u_n$ ជាអនុគមន៍នៃ $n$

ដោយ $(u_n)$ ជាស៊ីតធរណីមាត្រដែលមានផលធៀបរួម $q = 3$

យើងបាន
$$u_n = u_3 \cdot q^{n-3} = 27 \cdot 3^{n-3} = 3^3 \cdot 3^{n-3} = 3^n$$

ដូចនេះ $\boxed{u_n = 3^n}$

លំហាត់គំរូទី៦ : គេឱ្យ $(u_n)$ ជាស្វ៊ីតធរណីមាត្រ។ បើគេដឹងថា៖

ក. $u_3 = 18$ , $u_7 = 1458$ ។ គណនា $q$ និង $u_{10}$ ។

ខ. $u_3 = 20$ , $u_6 = 1280$ ។ គណនា $q$ និង $u_1$ ។

គ. $u_1 = 3$ , $u_3 = 21$ ។ គណនា $q$ ។

## ដំណោះស្រាយ

ក. គណនា $q$ និង $u_{10}$

យើងមាន $u_3 = 18$ , $u_7 = 1458$

យើងបាន $u_7 = u_3 \cdot q^{7-3}$

$1458 = 18 \cdot q^4$

$q^4 = 81$

$\Rightarrow q = \pm\sqrt[4]{81} = \pm 3$

- $u_{10} = u_3 \cdot q^{10-3}$

$= 18 \cdot (\pm 3)^7$

$= \pm 39366$

ដូចនេះ $q = \pm 3$ , $u_{10} = \pm 39366$

ខ. ចម្លើយគឺ $q = 4$ , $u_1 = \frac{5}{4}$

គ. ចម្លើយគឺ $q = \pm\sqrt{7}$

## លំហាត់អនុវត្តន៍

១. គេឱ្យ $(u_n)$ ជាស្វ៊ីតធរណីមាត្រដែល $\frac{u_8}{u_5} = 8$ ។ គណនាផលធៀបរួម $q$ ។

២. គេឱ្យស្វ៊ីតធរណីមាត្រ $4, 8, 16, \ldots$ ។

ក. កំណត់តួទី៩នៃស្វ៊ីតនេះ ។

ខ. តើចំនួន 16384 ត្រូវជាតួទីប៉ុន្មាននៃស្វ៊ីតនេះ ?

៣. កំណត់ចំនួនតួនៃស៊ីតធរណីមាត្រខាងក្រោម៖

ក. $16, 8, 4, \ldots, \frac{1}{32}$

ខ. $1, -4, 16, -64, \ldots, 65536$

៤. គេឱ្យស៊ីត $(u_n)$ កំណត់ដោយទំនាក់ទំនង $u_1 = 25$ និង $u_{n+1} = 5u_n$ , $n \in \mathbb{N}$ ។

ក. បង្ហាញថា $(u_n)$ ជាស៊ីតធរណីមាត្រ។

ខ. គណនា $u_n$ ជាអនុគមន៍នៃ $n$ ។

៥. គេឱ្យ $(u_n)$ ជាស៊ីតធរណីមាត្រដែល $u_3 = \frac{8}{27}$ និង $u_6 = \frac{64}{729}$ ។

គណនា $q$ និង $u_1$ ។

៦. រកតួទូទៅនៃស៊ីតធរណីមាត្រដែល $u_3 = 36$ និង $u_7 = 2916$ ។

៧. គណនាផលបូកស៊ីតធរណីមាត្រខាងក្រោម៖

ក. $1 - 2 + 4 - 8 + 16 - \cdots + 1024$

ខ. $\frac{3}{8} + \frac{3}{4} + \frac{3}{2} + \cdots + 96$

## ៣. ផលគុណតួស្មើចម្ងាយពីតួចុង

ឧទាហរណ៍៖ គេឱ្យស៊ីតធរណីមាត្រ $u_1, u_2, u_3, u_4, u_5, u_6$ ។ $u_1$ និង $u_6$ ហៅថាតួចុង។ $u_2$ និង $u_5$ ហើយ $u_3$ និង $_4$ ហៅថាតួនៅស្មើចម្ងាយពីតួចុង។

☞ **បង្ហាញថា** $\mathbf{u_1 \times u_6 = u_2 \times u_5 = u_3 \times u_4}$

សម្រាយ

តាមរូបមន្តតួទី $n$ នៃស៊ីតធរណីមាត្រ៖ $u_n = u_1 \cdot q^{n-1}$ យើងបាន៖

$$u_1 \times u_6 = u_1 \times (u_1 \cdot q^5) = u_1^2 \cdot q^5 \qquad (1)$$

$$u_2 \times u_5 = (u_1 \cdot q) \times (u_1 \cdot q^4) = u_1^2 \cdot q^5 \qquad (2)$$

$$u_3 \times u_4 = (u_1 \cdot q^2) \times (u_1 \cdot q^3) = u_1^2 \cdot q^5 \qquad (3)$$

តាម (1), (2) និង (3) យើងបាន $u_1 \times u_6 = u_2 \times u_5 = u_3 \times u_4$

**ជាទូទៅ** ផលគុណតួស្មើចម្ងាយពីតួចុង ស្មើនឹងផលគុណតួចុងទាំងពីរ។
គេកំណត់សរសេរ $\mathbf{u_p \times u_{n-p+1} = u_1 \times u_n}$
ឬ បើ $\mathbf{m+n=k+p}$ នោះ $\mathbf{u_m \times u_n = u_k \times u_p}$
ដែល **m,n,k,p** ជាចំនួនគត់ធម្មជាតិ $(\mathbb{N})$ ។

សម្គាល់: ករណីស្វ៊ីតធរណីមាត្រមាន ៖

☞ **ចំនួនតួជាចំនួនសេស**

EX : $u_1 , u_2 , u_3 , u_4 , u_5$ យើងបាន $u_1 \times u_5 = u_2 \times u_4 = u_3^2$

☞ **ចំនួនតួជាចំនួនគូ**

EX : $u_1 , u_2 , u_3 , u_4 , u_5 , u_6$ យើងបាន $u_1 \times u_6 = u_2 \times u_5 = u_3 \times u_4$

➢ **ករណីពិសេស**

បីចំនួនតគ្នា $\mathbf{a , b , c}$ ជាស្វ៊ីតធរណីមាត្រកាលណា $\mathbf{\frac{b}{a} = \frac{c}{b} = q}$ ថេរ ឬ $\mathbf{b^2 = a \times c}$ ។
( $\mathbf{b = \sqrt{a \times c}}$ នោះ **b** ហៅថាមធ្យមធរណីមាត្ររវាង **a** និង **c** )

☞ **ដើម្បីបង្ហាញឱ្យឃើញថា បីចំនួន a,b,c ជាស្វ៊ីតធរណីមាត្រ យើងត្រូវ បង្ហាញថា** $\mathbf{\frac{b}{a} = \frac{c}{b} = q}$ **ថេរ ឬ** $\mathbf{b^2 = a \times c}$ **។**

លំហាត់គំរូទី១ : គេឱ្យបីចំនួន $a , b , c$ ជាស្វ៊ីតធរណីមាត្រ ។ បង្ហាញថា $a^2 , b^2 , c^2$ ក៏ជាស្វ៊ីតធរណីមាត្រដែរ។

### ដំណោះស្រាយ

បង្ហាញថា $a^2, b^2, c^2$ ក៏ជាស្វ៊ីតធរណីមាត្រ

យើងមាន $a, b, c$ ជាស្វ៊ីតធរណីមាត្រ នោះ $b^2 = a\cdot c$

$$\Rightarrow \left(b^2\right)^2 = \left(a\cdot c\right)^2$$

$$\Rightarrow \left(b^2\right)^2 = a^2\cdot c^2$$

នោះ $b^2$ ជាមធ្យមធរណីមាត្ររវាង $a^2$ និង $c^2$ ។

ដូចនេះ បង្ហាញថា $a^2, b^2, c^2$ ក៏ជាស្វ៊ីតធរណីមាត្រដែរ

លំហាត់គំរូទី២ : តើគេត្រូវបន្ថែមចំនួនប៉ុន្មានទៅលើចំនួន $3, 24, 94$ ដើម្បីឱ្យបីចំនួនតគ្នា ជាស្វ៊ីតធរណីមាត្រ ?

### ដំណោះស្រាយ

រកចំនួនដែលត្រូវបន្ថែម

តាង $x$ ជាចំនួដែលត្រូវបន្ថែមលើ $3, 24, 94$

នោះចំនួនថ្មីគឺ $(3+x), (24+x), (94+x)$

ចំនួនថ្មី: $(3+x), (24+x), (94+x)$ ជាស្វ៊ីតធរណីមាត្រកាលណា:

$$(24+x)^2 = (3+x)\cdot(94+x)$$

$$576+48x+x^2 = 282+3x+94x+x^2$$

$$-49x = -294$$

$$\Rightarrow x = 6$$

ដូចនេះ ចំនួនដែលត្រូវបន្ថែមគឺ $6$

លំហាត់គំរូទី៣ : រកមធ្យមធរណីមាត្ររវាង $4$ និង $9$ ។

### ដំណោះស្រាយ

តាង $x$ ជាមធ្យមធរណីមាត្ររវាង $4$ និង $9$ នោះ $x = \sqrt{4\cdot 9} = 6$

ដូចនេះ មធ្យមធរណីមាត្ររវាង $4$ និង $9$ គឺ $6$

លំហាត់គំរូទី៤ : គេឱ្យស៊ីតធរណីមាត្រដែល $u_3 = 4$ និង $u_5 = 36$ ។
គណនា $u_1$ និង ផលធៀបរួម $q$ ។

## ដំណោះស្រាយ

របៀបទី១

ផលគុណតួស្មើចម្ងាយពីតួចុងយើងមាន $u_1 \times u_5 = u_3^2$

នោះ $u_1 = \frac{u_3^2}{u_5} = \frac{4^2}{36} = \frac{4}{9}$

ម្យ៉ាងទៀត $u_5 = u_3 \cdot q^2 \Rightarrow q = \pm\sqrt{\frac{u_5}{u_3}} = \pm\sqrt{\frac{36}{4}} = \pm 3$

ដូចនេះ $\boxed{u_1 = \frac{4}{5}\ ,\ q = \pm 3}$

របៀបទី២ :

យើងមាន $u_5 = u_3 \cdot q^{5-3}$

$36 = 4 \cdot q^2$

$q^2 = \frac{36}{4} = 9$

$\Rightarrow q = \pm\sqrt{9} = \pm 3$

ហើយ $u_1 = u_3 \cdot q^{1-3} = 4 \cdot (\pm 3)^{-2} = 4 \cdot \frac{1}{9} = \frac{4}{9}$

ដូចនេះ $\boxed{u_1 = \frac{4}{5}\ ,\ q = \pm 3}$

Note : ចំពោះលំហាត់នេះ បើគេឱ្យយើងរក $u_1$ រួចរក $q$ យើងត្រូវធ្វើតាមរបៀបទី១

# លំហាត់អនុវត្តន៍

១. គេឱ្យ $(u_n)$ ជាស្ទីតធរណីមាត្រដែល $u_3 = 12$ និង $u_{11} = 3072$ ។គណនា $u_7$ ។

២. គេឱ្យបីចំនួន $a, b, c$ ជាស្ទីតធរណីមាត្រ ។ ស្រាយបញ្ជាក់ថា ៖

ក. $\left(a^2+b^2\right)\left(b^2+c^2\right)=(ab+bc)^2$

ខ. $(ab+bc+ca)^3 = abc(a+b+c)^3$

៣. តើគេត្រូវបន្ថែមចំនួនប៉ុន្មានទៅលើចំនួន $4, 14, 30$ ដើម្បីឱ្យបានបីចំនួនតគ្នា ជាស្ទីតធរណីមាត្រ ?

៤. បើ $x, 2x+6, 4x+36$ បង្កើតបានជាស្ទីតធរណីមាត្រ ចូរគណនា $x$ ។

៥. រកតួទី១ $(u_1)$ និង ផលធៀបរួម $(q)$ នៃស្ទីតធរណីមាត្រខាងក្រោមៈ

ក. $u_3 = 1$ និង $u_7 = 81$ ។

ខ. $u_3 = 10$ និង $u_6 = 80$ ។

គ. $u_7 = 8u_4$ និង $u_{10} = 1024$ ។

ឃ. $u_2 + u_3 = 9$ និង $u_7 = 27u_4$ ។

៦. កំណត់ផលធៀបរួម $(q)$ និង តួទី១ $(u_1)$ នៃស្ទីតធរណីមាត្រចុះ $(u_n)_{n\in\mathbb{N}}$ បើគេដឹងថា $\begin{cases} u_1\cdot u_2\cdot u_3 = 64 \\ u_1^2+u_2^2+u_3^2 = 84 \end{cases}$ ។

៧. គេឱ្យ $a, b, c$ ជាស្ទីតធរណីមាត្រ។ ស្រាយបញ្ជាក់ថាៈ

ក. $\dfrac{1}{a^2}, \dfrac{1}{b^2}, \dfrac{1}{c^2}$ ជាស្ទីតធរណីមាត្រ។

ខ. $\dfrac{1}{a^p}, \dfrac{1}{b^p}, \dfrac{1}{c^p}$ ជាស្ទីតធរណីមាត្រ។

៨. គេឱ្យ $x, 28, y$ ជាស្ទីតធរណីមាត្រ និង $x + y = 119$ ។ គណនា $x$ និង $y$ ។

# ៤. ផលបូកតួនៃស៊ីតធរណីមាត្រ

ផលបូកតួនៃស៊ីតធរណីមាត្រដែលមាន $\mathbf{u_1}$ ជាតួទី១ និង $\mathbf{q}$ ជាផលធៀបរួម $(q \neq 0)$ គឺ $\mathbf{S_n = u_1 \times \frac{q^n - 1}{q - 1}}$ ឬ $\mathbf{S_n = u_1 \times \frac{1 - q^n}{1 - q}}$

**សម្រាយ**

## របៀបទី១

តាង $S_n = u_1 + u_2 + u_3 + \cdots + u_n \quad (1)$

គុណ (1) នឹងផលធៀបរួម $q$

យើងបាន $qS_n = u_1 \cdot q + u_2 \cdot q + u_3 \cdot q + \cdots + u_n \cdot q$

$$= u_2 + u_3 + u_4 + \cdots + u_{n+1} \qquad (2)$$

យក $(2)-(1)$ យើងបាន $(q-1)S_n = u_{n+1} - u_1 = u_1 \cdot q^n - u_1 = u_1\left(q^n - 1\right)$

$$\Rightarrow S_n = \frac{u_1\left(q^n - 1\right)}{q - 1}$$

ដូចនេះ $\mathbf{S_n = u_1 \times \frac{q^n - 1}{q - 1}}$

## របៀបទី២

តាង $S_n = u_1 + u_2 + u_3 + \cdots + u_n$

$$= u_1 + (u_1 \cdot q) + (u_1 \cdot q^2) + \cdots + (u_1 \cdot q^{n-1})$$

$$S_n = u_1\left(1 + q + q^2 + \cdots + q^{n-1}\right) \quad (*)$$

គុណអង្គទាំងពីរនៃ $(*)$ នឹង $(1-q)$ យើងបានៈ

$$(1-q)S_n = u_1(1-q)\left(1 + q + q^2 + \cdots + q^{n-1}\right) = u_1\left(1 - q^n\right)$$

$$\Rightarrow \mathbf{S_n = \frac{u_1\left(1 - q^n\right)}{1 - q}}$$

លំហាត់គំរូទី១ : គណនាផលបូក $n$ តួដំបូងនៃស្វ៊ីតធរណីមាត្រខាងក្រោម៖

ក. $3+12+48+\cdots$

ខ. $125-25+5+\cdots$

## ដំណោះស្រាយ

ក. តាង $S_n=3+12+48+\cdots$

យើងមាន $q=\dfrac{12}{3}=4$

យើងបាន $S_n=u_1\dfrac{q^n-1}{q-1}$

$=3\cdot\dfrac{4^n-1}{4-1}$

$=4^n-1$

ដូចនេះ $\boxed{S_n=4^n-1}$

ខ. តាង $S_n=125-25+5+\cdots$

យើងមាន $q=\dfrac{-25}{125}=-\dfrac{1}{5}$

យើងបាន $S_n=u_1\cdot\dfrac{1-q^n}{1-q}$

$$=125\frac{1-\left(-\frac{1}{5}\right)^n}{1+\frac{1}{5}}$$

$$=125\cdot\frac{5}{6}\left[1-\left(-\frac{1}{5}\right)^n\right]$$

$$=\frac{625}{6}\left[1-\left(-\frac{1}{5}\right)^n\right]$$

ដូចនេះ $S_n = \frac{625}{6}\left[1-\left(-\frac{1}{5}\right)^n\right]$

លំហាត់គំរូទី២ : គេឱ្យស្វ៊ីតធរណីមាត្រ $6, 3, 1.5, 0.75, \ldots$ ។

ក. គណនាតួទី៧ ។

ខ. គណនាផលបូក ៧ តួដំបូងនៃស្វ៊ីតនេះ ។

## ដំណោះស្រាយ

ក. គណនាតួទី៧

យើងមានស្វ៊ីតធរណីមាត្រ $6, 3, 1.5, 0.75, \ldots$

នោះ $q = \frac{3}{6} = \frac{1}{2} = 0.5$

យើងបាន $u_7 = u_1 \cdot q^{7-1}$

$= 6 \cdot (0.5)^6$

$= 0.09375$

ដូចនេះ $u_7 = 0.09375$

ខ. គណនាផលបូក ៧ តួដំបូងនៃស្វ៊ីតនេះ

តាមរូបមន្ត $S_n = u_1 \frac{1-q^n}{1-q}$

យើងបាន $S_7 = u_1 \cdot \frac{1-q^7}{1-q}$

$= 6 \cdot \frac{1-(0.5)^7}{1-0.5}$

$= \frac{6 \times 0.9921875}{0.5}$

$= 11.90625$

ដូចនេះ $S_7 = 11.90625$

លំហាត់គំរូទី៣ : គណនាផលបូកស៊ីតធរណីមាត្រខាងក្រោម :

ក. $48+24+12+\cdots+\frac{3}{8}$

ខ. $2+4+8+\cdots+512$

## ដំណោះស្រាយ

ក. $48+24+12+\cdots+\frac{3}{8}$

**របៀបទី១**

$$S_n = 48+24+12+\cdots+\frac{3}{8}$$

នោះ $q=\frac{24}{48}=\frac{1}{2}$

តាង $n$ ជចំនួនតួ ដែល $u_n=\frac{3}{8}$

តែ $u_n = u_1\cdot q^{n-1} = 48\cdot\left(\frac{1}{2}\right)^{n-1} = \frac{48}{2^{n-1}} = \frac{96}{2^n}$

នោះ $\frac{96}{2^n}=\frac{3}{8}$

$$2^n = \frac{96\times 8}{3} = 256 = 2^8$$

$$\Rightarrow n = 8$$

យើងបាន $S_8 = u_1\frac{1-q^8}{1-q}$

$$= 48\cdot\frac{1-\left(\frac{1}{2}\right)^8}{1-\frac{1}{2}} = \frac{765}{8}$$

ដូចនេះ $\boxed{48+24+12+\cdots+\frac{3}{8}=\frac{765}{8}}$

## របៀបទី២

នោះ $q=\frac{24}{48}=\frac{1}{2}$

ហើយ $u_n=\frac{3}{8}\Rightarrow u_{n+1}=\frac{3}{8}\cdot\frac{1}{2}=\frac{3}{16}$

យើងបាន $S_n=\frac{u_1(1-q^n)}{1-q}=\frac{u_1-u_{n+1}}{1-q}$

$$=\frac{48-\frac{3}{16}}{1-\frac{1}{2}}=\frac{765}{8}$$

ដូចនេះ $\boxed{48+24+12+\cdots+\frac{3}{8}=\frac{765}{8}}$

ខ. $2+4+8+\cdots+512$

## របៀបទី១

$S_n=2+4+8+\cdots+512$

នោះ $q=\frac{4}{2}=2$

តាង $n$ ជចំនួនតួ ដែល $u_n=512$

តែ $u_n=u_1\cdot q^{n-1}=2\cdot 2^{n-1}=2^n$

នោះ $2^n=512=2^9 \quad \Rightarrow n=9$

យើងបាន $S_8=u_1\frac{1-q^8}{1-q}$

$$=2\cdot\frac{2^9-1}{2-1}=1022$$

ដូចនេះ $\boxed{2+4+8+\cdots+512=1022}$

របៀបទី២

$S_n = 2+4+8+\cdots+512$

នោះ $q=\frac{4}{2}=2$ ហើយ $u_n = 512 \Rightarrow u_{n+1} = 512\cdot 2 = 1024$

យើងបាន $S_n = \frac{u_1(q^n-1)}{q-1} = \frac{u_{n+1}-u_1}{q-1}$

$= \frac{1024-2}{2-1} = 1022$

ដូចនេះ $\boxed{2+4+8+\cdots+512=1022}$

លំហាត់គំរូទី៤ : គណនា

ក. $S_n = 9+99+999+\cdots+\underbrace{999\ldots9}_{n\text{ដងលេខ }9}$

ខ. $S_n = 7+77+777+\cdots+\underbrace{777\ldots7}_{n\text{ដងលេខ }7}$

## ដំណោះស្រាយ

ក. $S_n = 9+99+999+\cdots+\underbrace{999\ldots9}_{n\text{ដងលេខ }9}$

$=(10-1)+\left(10^2-1\right)+\left(10^3-1\right)+\cdots+\left(10^n-1\right)$

$=\left(10+10^2+10^3+\cdots+10^n\right)-(1+1+1+\cdots+1)$

$=10\cdot\frac{10^n-1}{10-1}-n$

$=\frac{10^{n+1}-9n-10}{9}$

ដូចនេះ $\boxed{S_n = 9+99+999+\cdots+\underbrace{999\ldots9}_{n\text{ដងលេខ }9} = \frac{10^{n+1}-9n-10}{9}}$

ខ. $S_n = 7+77+777+\cdots+\underbrace{777\ldots7}_{n\text{ ដងលេខ }7}$

$$= \frac{7}{9}(9+99+999+\cdots+\underbrace{999\ldots9}_{n\text{ ដងលេខ }9})$$

$$= \frac{7}{9}\left[(10-1)+(10^2-1)+(10^3-1)+\cdots+(10^n-1)\right]$$

$$= \frac{7}{9}\left[(10+10^2+10^3+\cdots+10^n)-(1+1+1+\cdots+1)\right]$$

$$= \frac{7}{9}\left(10\cdot\frac{10^n-1}{10-1}-n\right)$$

$$= \frac{7}{9}\cdot\frac{10^{n+1}-9n-10}{9}$$

$$= \frac{7}{81}\left(10^{n+1}-9n-10\right)$$

ដូចនេះ $S_n = 7+77+777+\cdots+\underbrace{777\ldots7}_{n\text{ ដងលេខ }7} = \frac{7}{81}\left(10^{n+1}-9n-10\right)$

លំហាត់គំរូទី៥ : គេឱ្យការេមួយដែលមានរង្វាស់ជ្រុងស្មើនឹង $a$ ។ គេសង់ការេមួយទៀតមានកំពូលជាចំណុចកណ្ដាលរៀងគ្នានៃការេមុន។ គេសង់ការេរបៀបនេះរហូតដល់ $n$ ការេ។

ក. គណនាផ្ទៃក្រឡាការេទី $n$ ។

ខ. គណនាផលបូកផ្ទៃក្រឡាទាំងអស់ ។

## ដំណោះស្រាយ




ក. គណនាផ្ទៃក្រឡាការេទី $n$

តាង $d_1, d_2, d_3, \ldots, d_n$ ជារង្វាស់ជ្រុងនៃការេទាំងនោះ ហើយ តាង $A_1, A_2, A_3, \ldots, A_n$ ជាផ្ទៃក្រឡានៃការេទាំងនោះ

យើងបាន
- $d_1 = a \Rightarrow A_1 = d_1^2 = a^2$
- $d_2 = \left(\frac{a}{2}\right)\sqrt{2} \Rightarrow A_2^2 = \left(\frac{a\sqrt{2}}{2}\right)^2 = \frac{a^2}{2}$
- $d_3 = \left(\frac{\frac{a\sqrt{2}}{2}}{2}\right)\sqrt{2} = \frac{a}{2} \Rightarrow A_3^2 = \frac{a^2}{4}$

..........................................................

..........................................................

នោះ $(A_n): A_1 , A_2 , A_3 , \ldots$ ដែល $A_1 = a^2 , A_2 = \frac{a^2}{2} , A_3 = \frac{a^2}{4} , \ldots$

ជាស៊ីតធរណីមាត្រ ដែលមានផលធៀបរួម $q = \frac{1}{2}$

យើងបាន $A_n = A_1 \cdot q^{n-1}$

$$= a^2 \cdot \left(\frac{1}{2}\right)^{n-1}$$

$$= \frac{a^2}{2^{n-1}}$$

ដូចនេះ ផ្ទៃក្រឡាការេទី $n$ គឺ $\boxed{A_n = \frac{a^2}{2^{n-1}}}$

ខ. គណនាផលបូកផ្ទៃក្រឡាទាំងអស់

តាង $S_n$ ជាផលបូកផ្ទៃក្រឡាទាំងអស់

យើងបាន $S_n = A_1 + A_2 + A_3 + \cdots + A_n$

$$= A_1 \cdot \frac{1-q^n}{1-q}$$

$$= a^2 \frac{1-\left(\frac{1}{2}\right)^n}{1-\frac{1}{2}}$$

$$= \frac{a^2(2^n-1)}{2^{n-1}}$$

ដូចនេះ ផលបូកផ្ទៃក្រឡាទាំងអស់គឺ $S_n = \frac{a^2(2^n-1)}{2^{n-1}}$

## លំហាត់អនុវត្តន៍

១. គណនាផលបូក $n$ តួដំបូងនៃស៊ីតធរណីមាត្រខាងក្រោម៖

ក. $\left(\frac{2}{3}\right)+\left(\frac{2}{3}\right)^2+\left(\frac{2}{3}\right)^3+\cdots+\left(\frac{2}{3}\right)^n$

ខ. $\frac{1}{4}+\frac{1}{2}+1+2+\cdots$

២. គេមានស៊ីតធរណីមាត្រ $1,-2,4,-8,\ldots$ ។

ក. គណនាតួទី $11$ ។

ខ. គណនាផលបូក $11$ តួដំបូងនៃស៊ីតនេះ ។

៣. គណនាផលបូកស៊ីតធរណីមាត្រខាងក្រោម៖

ក. $100+50+25+\cdots+\frac{25}{16}$

ខ. $-100+50-25+\cdots+\frac{25}{128}$

៤. គណនាផលបូកខាងក្រោម៖

ក. $S_n = 8+88+888+\cdots+\underbrace{888\ldots8}_{n\text{ដងលេខ}8}$

ខ. $18+198+1998+19998+\cdots+1999\ldots998$ , $(n-1)$ដងលេខ8

គ. $S_n = 25 + 2525 + 252525 + \cdots + \underbrace{252525\ldots25}_{25\text{ចំនួន } n \text{ ដង}}$

ឃ. $2013 + 20132013 + 201320132013 + \cdots + \underbrace{201320132013\ldots2013}_{2013\text{ចំនួន } n \text{ ដង}}$

៥. គណនាផលបូកស្វ៊ីតខាងក្រោម:

ក. $S_n = 1\cdot2 + 2\cdot4 + 3\cdot8 + 4\cdot16 + \cdots + n\cdot2^n$

ខ. $T_n = 2 + 4x + 6x^2 + 8x^3 + \cdots + 2nx^{n-1}$

៦. គេមានការេមួយដែលជ្រុងវាមានរង្វាស់ $8cm$ ។ គេសង់ការេមួយទៀតដែលកំពូលវាជាចំណុចកណ្ដាលរៀងគ្នានៃនៃជ្រុងការេមុន។ គេសង់ការេបន្តបន្ទាប់របៀបនេះ រហូតបានការេ 8 ។

ក. គណនាប្រវែងជ្រុងទីមួយនៃការេទាំងនោះ ។

ខ. គណនាផលបូកវិមាត្រនៃការេទាំងអស់ ។

គ. គណនាផលបូកផ្ទៃក្រឡានៃការេទាំងអស់ ។

## ៥. ស្វ៊ីតធរណីមាត្រអនន្តតួ

យើងមាន $S_n = u_1 + u_2 + u_3 + \cdots + u_n$

នោះផលបូកអនន្តតួកំណត់ដោយ $S_\infty = u_1 + u_2 + u_3 + \cdots + u_n + \cdots$

ដោយ $S_n = \dfrac{u_1(1-q^n)}{1-q} = \dfrac{u_1}{1-q} - \dfrac{u_1q^n}{1-q}$

❶ បើ $|q| < 1$ នោះ $q^n \to 0$ កាលណា $n \to \infty$

នោះ $S_n = \dfrac{u_1(1-q^n)}{1-q} = \dfrac{u_1}{1-q} - \dfrac{u_1q^n}{1-q}$

$\Rightarrow S_\infty = \dfrac{u_1}{1-q} - \dfrac{u_1\cdot0}{1-q} = \dfrac{u_1}{1-q}$

❷ បើ $|q| > 1$ នោះ $q^n \to \infty$ កាលណា $n \to \infty$

នោះ $S_\infty$ មិនកំណត់

❸ បើ $q=\pm 1$ នោះ $\left[\begin{array}{l} S_\infty = u_1+u_1+u_1+u_1+\cdots \\ S_\infty = u_1-u_1+u_1-u_1+\cdots \end{array}\right.$ មិនកំណត់

**ជាទូទៅ**

- **បើ $|q|<1$ នោះផលបូកតួនៃស៊ីតធរណីមាត្រអនន្តតួ**

  **កំណត់ដោយ: $S_\infty = \dfrac{u_1}{1-q}$**

- **បើ $|q|\geq 1$ នោះ $S_\infty$ មិនអាចកំណត់បាន**

លំហាត់គំរូទី១ : គណនាផលបូកស៊ីតធរណីមាត្រអនន្តតួ $16+12+9+\cdots$ ។

**ដំណោះស្រាយ**

យើងមាន $u_1=16$ ហើយ $q=\dfrac{12}{16}=\dfrac{3}{4}<1$

យើងបាន $S_\infty=\dfrac{u_1}{1-q}=\dfrac{16}{1-\dfrac{3}{4}}=64$

ដូចនេះ $\boxed{S_\infty=64}$

លំហាត់គំរូទី២ : គណនាផលបូកតួនៃស៊ីតធរណីមាត្រ $3+\dfrac{3}{4}+\dfrac{3}{16}+\cdots$ ។

**ដំណោះស្រាយ**

យើងមាន $u_1=3$ ហើយ $q=\dfrac{3}{4}\div 3=\dfrac{1}{4}<1$

យើងបាន $S_\infty=\dfrac{u_1}{1-q}=\dfrac{3}{1-\dfrac{1}{4}}=4$

ដូចនេះ $\boxed{S_\infty=4}$

លំហាត់គំរូទី៣ : គណនាផលធៀបរួមនៃស៊ីតធរណីមាត្រអនន្តតួ ដែលមាន $u_1 = 5$ និង $S_\infty = 15$ ។

## ដំណោះស្រាយ

យើងមាន $u_1 = 5$ និង $S_\infty = 15$

តាម ផលបូកស៊ីតធរណីមាត្រអនន្តតួ $S_\infty = \frac{u_1}{1-q}$

យើងបាន $15 = \frac{5}{1-q}$

$$15 - 15q = 5$$

$$-15q = -10$$

$$q = \frac{-10}{-15} = \frac{2}{3}$$

ដូចនេះ $\boxed{q = \frac{2}{3}}$

លំហាត់គំរូទី៤ : សរសេរចំនួនទសភាគខួបខាងក្រោមជាទម្រង់ប្រភាគ $\frac{a}{b}$ ៖

ក. $0.\overline{7}$ ខ. $2.\overline{34}$ គ. $0.\overline{235}$

## ដំណោះស្រាយ

ក. $0.\overline{7} = 0.7777777\ldots \quad = 0.7 + 0.07 + 0.007 + \cdots$

ជាផលបូកតួនៃស៊ីតធរណីមាត្រអនន្តតួដែលមាន $u_1 = 0.7 = \frac{7}{10}$

និង $q = 0.1 = \frac{1}{10}$

តាមរូបមន្ត $S_\infty = \frac{u_1}{1-q}$ យើងបាន $0.\overline{7} = \frac{7}{10} \div \left(1 - \frac{1}{10}\right) = \frac{7}{9}$

ដូចនេះ $\boxed{0.\overline{7} = \frac{7}{9}}$

របៀម្យ៉ាងទៀត

តាង $N = 0.\overline{7} = 0.7777\ldots \quad (1)$

គុណ (1) នឹង 10 យើងបាន $10N = 7.7777\ldots \quad (2)$

យក $(2)-(1)$ យើងបាន $9N = 7 \Rightarrow N = \frac{7}{9}$

ដូចនេះ $\boxed{0.\overline{7} = \frac{7}{9}}$

ខ. $2.\overline{34} = 2 + 0.\overline{34} = 2 + 0.34 + 0.0034 + 0.000034 + \ldots$

$$= 2 + \frac{0.34}{1-0.01} = 2 + \frac{0.34}{0.99}$$

$$= 2 + \frac{34}{99}$$

$$= \frac{232}{99}$$

ដូចនេះ $\boxed{2.\overline{34} = \frac{232}{99}}$

របៀបម្យ៉ាងទៀត

តាង $N = 2.\overline{34} = 2.343434\ldots \quad (1)$

នោះ $100N = 234.343434\ldots \quad (2)$

យក $(2)-(1)$ យើងបាន $99N = 232 \Rightarrow N = \frac{232}{99}$

ដូចនេះ $\boxed{2.\overline{34} = \frac{232}{99}}$

គ. $0.\overline{235} = 0.235235235 = 0.235 + 0.000235 + 0.000000235 + \ldots$

$$= \frac{0.235}{1-0.001} = \frac{0.235}{0.999} = \frac{235}{999}$$

ដូចនេះ $0.\overline{235}=\dfrac{235}{999}$

របៀបម្យ៉ាងទៀត

តាង $N=0.\overline{235}=0.235235235\ldots \quad (1)$

នោះ $1000N=235.235235235\ldots \quad (2)$

យក $(2)-(1)$ យើងបាន $999N=235\Rightarrow N=\dfrac{235}{999}$

ដូចនេះ $0.\overline{235}=\dfrac{235}{999}$

លំហាត់គំរូទី៥ : បុរសម្នាក់បានលោតពីលើស្ពានដោយចងខ្សែពួរទៅនឹងជើងរបស់គាត់ប្រវែង $120\,m$ ហើយយឺតឡើងមកវិញបាន $\frac{1}{3}$ នៃប្រវែងដើម។ រាល់ពេលដែលយឺតឡើង វាធ្លាក់ចុះមកវិញបាន $\frac{2}{3}$ នៃប្រវែងដែលយឺតតឡើង។ គណនាប្រវែងខ្សែសរុបចាប់តាំងពីគាត់លោតចុះ រហូតដល់ខ្សែមានលំនឹង។

**ដំណោះស្រាយ**




គណនាប្រវែងខ្សែសរុបចាប់តាំងពីគាត់លោតចុះ រហូតដល់ខ្សែមានលំនឹង

តាមបំរាប់ យើងបាន:

- $u_1=120$
- $u_2=\dfrac{1}{3}u_1$
- $u_3=\dfrac{2}{3}u_2=\dfrac{2}{3}\cdot\dfrac{1}{3}u_1=\dfrac{2}{3^2}u_1$
- $u_4=\dfrac{1}{3}u_3=\dfrac{1}{3}\cdot\dfrac{2}{3^2}u_1=\dfrac{2}{3^3}u_1$

- $u_5 = \frac{2}{3}u_4 = \frac{2}{3}\cdot\frac{2}{3^3}u_1 = \frac{2^2}{3^4}u_1$
- $u_6 = \frac{1}{3}u_5 = \frac{1}{3}\cdot\frac{2^2}{3^4}u_1 = \frac{2^2}{3^5}u_1$
- $u_7 = \frac{2}{3}u_6 = \frac{2}{3}\cdot\frac{2^2}{3^5}u_1 = \frac{2^3}{3^6}u_1$
- $u_8 = \frac{1}{3}u_7 = \frac{1}{3}\cdot\frac{2^3}{3^6}u_1 = \frac{2^3}{3^7}u_1$

..........................................

..........................................

តាង $S$ ជាប្រវែងខ្សែសរុបនៃការធ្លាក់ចុះ និង យឺតឡើង

យើងបាន:

$$S = u_1 + u_2 + u_3 + u_4 + u_5 + u_6 + u_7 + u_8 + \dots$$

$$= u_1 + \frac{1}{3}u_1 + \frac{2}{3^2}u_1 + \frac{2}{3^3}u_1 + \frac{2^2}{3^4}u_1 + \frac{2^2}{3^5}u_1 + \frac{2^3}{3^6}u_1 + \frac{2^3}{3^7}u_1 + \dots$$

$$= u_1\left[\left(1 + \frac{2}{3^2} + \frac{2^2}{3^4} + \frac{2^3}{3^6} + \cdots\right) + \left(\frac{1}{3} + \frac{2}{3^3} + \frac{2^2}{3^5} + \frac{2^3}{3^7} + \cdots\right)\right]$$

$$= u_1\left(\frac{1}{1-\frac{2}{3^2}} + \frac{\frac{1}{3}}{1-\frac{2}{3^2}}\right)$$

$$= u_1\left(\frac{9}{7} + \frac{3}{7}\right)$$

$$= \frac{12u_1}{7}$$

$$= \frac{12\times 120}{7} = \frac{1440}{7} = 205.71$$

ដូចនេះ ប្រវែងខ្សែសរុបចាប់តាំងពីគាត់លោតចុះ រហូតដល់ខ្សែមានលំនឹង

គឺ $\boxed{S = 205.71m}$

# លំហាត់អនុវត្តន៍

១. គណនាផលបូកនៃស្វ៊ីតធរណីមាត្រអនន្តតួ ដែលកំណត់ដូចខាងក្រោម៖

ក. $\frac{9}{4}+\frac{3}{2}+1+\cdots$ ខ. $100+50+25+\cdots$

គ. $-20+10-5+\cdots$ ឃ. $12+4+\frac{4}{3}+\cdots$

២. គណនាផលធៀបរួមនៃស្វ៊ីតធរណីមាត្រអនន្តតួដែលមាន៖

ក. $u_1=8$ និង $S_\infty=10$ ខ. $u_1=4$ និង $S_\infty=12$

៣. សរសេរចំនួនទសភាគខួបខាងក្រោមជាប្រភាគសនិទាន $\frac{a}{b}$

ក. $0.\overline{5}$ ខ. $0.\overline{50}$

គ. $0.4\overline{52}$ ឃ. $0.2\overline{35}$

៤. រកតួដំបូងនៃស្វ៊ីតធរណីមាត្រអនន្តតួដែលមានផលធៀបរួម $q=\frac{3}{5}$ និង ផលបូកអនន្តតួ $S_\infty=40$ ។

៥. ផលបូ២ តួដំបូងនៃស្វ៊ីតធរណីមាត្រស្មើនឹង 9 ហើយផលបូកអនន្តតួនៃស្វ៊ីតធរណីមាត្រនេះស្មើនឹង 25 ។ បើស្វ៊ីតធរណីមាត្រនេះមាន ផលធៀបរួម $r$ ជាចំនួនវិជ្ជមាន គណនា $r$ និង តួដំបូង ។

៦. គេសង្កេតមុខនាឡិកាមួយ ។ នៅពេលទ្រនិចម៉ោង និង ទ្រនិចនាទីកំពុងតែត្រួតស៊ីគ្នា កំណត់រយៈពេលដែលទ្រនិចទាំងពីរជួបគ្នាលើកទី២ ។

៧. បាល់មួយត្រូវបានគេទម្លាក់ពីកម្ពស់ $12m$ ។ រាល់ពេលដែលវាធ្លាក់ទៅប៉ះដី បាល់នោះលោតឡើងវិញបានកម្ពស់ $\frac{3}{4}$ នៃកម្ពស់ដែលវាធ្លាក់។ គណនាប្រវែងសរុប ដែលបាល់លោតចុះឡើង ដោយគិតចាប់តាំងពីបាល់ធ្លាក់ចុះ រហូតដល់វាមានលំនឹង។

# លំហាត់

១. រកតួទី $n$ នៃស្វ៊ីតធរណីមាត្រខាងក្រោម :

ក. $125\,,25\,,5\,,...$ ខ. $-3\,,9\,,-27\,,...$

២. គេឱ្យស្វ៊ីតធរណីមាត្រ $2\,,6\,,18\,,...$ ។

ក. គណនាតួទី៨ នៃស្វ៊ីតនេះ ។

ខ. តើចំនួន 486 ត្រូវជាតួទីប៉ុន្មាននៃស្វ៊ីតនេះ ?

៣. រកចំនួនតួនៃស្វ៊ីតធរណីមាត្រខាងក្រោម :

ក. $2\,,4\,,8\,,...\,,512$ ខ. $81\,,27\,,9\,,...\,,\dfrac{1}{27}$

៤. គេឱ្យ $(u_n)_{n\in\mathbb{N}}$ ជាស្វ៊ីតធរណីមាត្រ បើគេដឹងថា :

ក. $U_3=18$ , $U_7=1458$ ។ គណនា $q$ និង $U_{10}$ ។

ខ. $U_1=3$ , $S_3=21$ ។ គណនា $q$ និង $S_7$ ។

៥. គណនាផលបូកស្វ៊ីតធរណីមាត្រខាងក្រោម :

ក. $48+24+12+...+\dfrac{3}{8}$ ខ. $9-6+4-...-\dfrac{128}{243}$

គ. $100+50+25+...+\dfrac{25}{16}$ ឃ. $\dfrac{2}{3}+\left(\dfrac{2}{3}\right)^2+\left(\dfrac{2}{3}\right)^3+...+\left(\dfrac{2}{3}\right)^n$

ង. $\dfrac{1}{3}+1+3+...+6561$ ច. $-100+50-25+...+\dfrac{25}{128}$

ឆ. $1-\dfrac{1}{2}+\dfrac{1}{3^2}-\dfrac{1}{2^3}+\dfrac{1}{3^4}-\dfrac{1}{2^5}+...-\dfrac{1}{2^{2n-1}}+\dfrac{1}{3^{2n}}$

៦. គណនាផលបូកស្វ៊ីតធរណីមាត្រអនន្តតួដែលមាន $U_2=-9$ និង $U_5=\dfrac{1}{3}$

៧. គណនាផលធៀបរួមនៃស្វ៊ីតធរណីមាត្រអនន្តតួដែលមាន $U_1=5$ និង $S_\infty=15$

៨. ផលបូកពីរតួដំបូងនៃស្វ៊ីតធរណីមាត្រស្មើនឹង 9 និងផលបូកស្វ៊ីត ធរណី-មាត្រ អនន្តតួស្មើនឹង 25 ។ គណនា $q$ និង $U_1$ បើផលធៀបរួម $q>0$ ។

៩. តួទី៣ នៃស្វ៊ីតធរណីមាត្រស្មើនឹង 3 និង តួទី៦ ស្មើនឹង $\dfrac{3}{8}$ ។

គណនាផលធៀបរួម និង ផលបូក ៨ តួដំបូង ។

១០. គណនា $a$ ដើម្បីឱ្យចំនួន $(a-3)$ , $(a+1)$ , $(4a-2)$ ជាបីតួតគ្នា នៃស្វ៊ីតធរណីមាត្រ ។

១១. ក. ដោះស្រាយសមីការ $3x^2-8x+4=0$ $(E)$ ក្នុងសំណុំ $\mathbb{R}$ ។

ខ. គេមាន $(U_n)_{n\in\mathbb{N}}$ ជាស្វ៊ីតធរណីមាត្រកើនដែលមាន $U_3$ និង $U_4$ នៃស្វ៊ីតនេះជាចម្លើយនៃសមីការ $(E)$ ។

a) ទាញរកផលធៀបរួមនៃស្វ៊ីតនេះ ។

b) គណនាតួទីមួយ $(U_1)$ នៃស្វ៊ីតនេះ ។

១២. គេឱ្យ $(U_n)$ ជាស្វ៊ីតធរណីមាត្រដែល $U_3=12$ និង $U_{11}=3072$ ។ គណនា $U_7$ ។

១៣. គណនាតួទី១ $(U_1)$ និងផលធៀបរួម $(q)$ នៃស្វ៊ីតធរណីមាត្រខាងក្រោម:

ក. $U_3=10$ និង $U_6=80$ ខ. $U_7=8U_4$ និង $U_{10}=1024$

គ. $U_2+U_3=9$ និង $U_7=27U_4$ ឃ. $U_n=\left(-\frac{1}{2}\right)^n$

១៤. បើ $x$ , $2x+6$ , $4x+36$ បង្កើតបានជាស្វ៊ីតធរណីមាត្រ ចូរគណនា $x$ ។

១៥.គេមាន $x,28,y$ ជាស្វ៊ីតធរណីមាត្រ និង $x+y=119$ ។ គណនា $x$ និង $y$ ។

១៦ រកបីតួដំបូងនៃស្វ៊ីតធរណីមាត្រមួយ ដែលមានផលបូកបីតួនេះស្មើ 26 ហើយផលគុណរបស់វាស្មើ 216 ។

១៧. រកពីរចំនួនខុសគ្នា $a$ និង $b$ ដែល $a$ , $b$ , 10 បង្កើតបានជាស្វ៊ីតនពន្ត ហើយ $b$ , $a$ , 10 បង្កើតបានជាស្វ៊ីតធរណីមាត្រ ។

១៨.ផលគុណបីតួដំបូងនៃស្វ៊ីតធរណីមាត្រមួយស្មើ 216 ហើយផលបូកបីតួដំបូងនេះស្មើ 21 ។ រកបីតួដំបូងនៃស្វ៊ីតនេះ បើគេដឹងថា ផលធៀបរួមរបស់វាតូចជាង 1 ។

# មេរៀនទី ៤ ផលបូកតួនៃស៊្វីតផ្សេងៗ

## ១. របៀបគណនាផលបូក

លំហាត់គំរូទី១ : គណនាផលបូកតួនៃស្វ៊ីតខាងក្រោម:

ក. $1+2+3+...+n$

ខ. $1^2+2^2+3^2+...n^2$

គ. $1^3+2^3+3^3+...+n^3$

**ដំណោះស្រាយ**

ក. តាង $S_n=1+2+3+...+(n-2)+(n-1)+n \quad (1)$

ឬ $S_n=n+(n-1)+(n-2)+...+3+2+1 \quad (2)$

$(1)+(2)$ យើងបាន៖

$$2S_n=\underbrace{(n+1)+(n+1)+(n+1)+...+(n+1)}_{n\text{ តួនៃ}(n+1)}=n(n+1)$$

$$\Rightarrow S_n=\frac{n(n+1)}{2}$$

ដូចនេះ $\boxed{1+2+3+...+n=\frac{n(n+1)}{2}}$

ខ. តាង $S_n=1^2+2^2+3^2+...+n^2$

យើងមាន $(k+1)^3=k^3+3k^2+3k+1$

$\Leftrightarrow 3k^2=(k+1)^3-k^3-3k-1$

យក $k=1,2,3,...,n$ យើងបាន :

$$+\begin{cases} k=1 \Rightarrow\ 3\cdot 1^2 = 2^3 - 1^3 - 3\cdot 1 - 1 \\ k=2 \Rightarrow\ 3\cdot 2^2 = 3^3 - 2^3 - 3\cdot 2 - 1 \\ k=3 \Rightarrow\ 3\cdot 3^2 = 4^3 - 3^3 - 3\cdot 3 - 1 \\ \vdots \qquad \vdots \qquad \vdots \quad \vdots \quad \vdots \\ k=n \Rightarrow 3\cdot n^2 = (n+1)^3 - n^3 + 3\cdot n - 1 \end{cases}$$

$$3S_n = (n+1)^3 - 1^3 - 3(1+2+3+\ldots+n) - n$$

$$= (n+1)^3 - 3\cdot\frac{n(n+1)}{2} - (n+1)$$

$$= \frac{(n+1)}{2}\left[2(n+1)^2 - 3n - 2\right]$$

$$= \frac{(n+1)}{2}(2n^2 + 4n + 2 - 3n - 2)$$

$$= \frac{(n+1)}{2}(2n^2 + n)$$

$$= \frac{n(n+1)(2n+1)}{2}$$

$$\Rightarrow\ S_n = \frac{n(n+1)(2n+1)}{6}$$

ដូចនេះ $\boxed{1^2 + 2^2 + 3^2 + \ldots + n^2 = \frac{n(n+1)(2n+1)}{6}}$

គ. តាង $S_n = 1^3 + 2^3 + 3^3 + \ldots + n^3$

យើងមាន $(k+1)^4 = k^4 + 4k^3 + 6k^2 + 4k + 1$

$$\Leftrightarrow 4k^3 = (k+1)^4 - k^4 - 6k^2 - 4k - 1$$

យក $k = 1\,,\,2\,,\,3\,,\ldots,\,n$ យើងបាន :

$$+\begin{cases} k=1 \Rightarrow\ 4\cdot 1^3 = 2^4 - 1^4 - 6\cdot 1^2 - 4\cdot 1 - 1 \\ k=2 \Rightarrow\ 4\cdot 2^3 = 3^4 - 2^4 - 6\cdot 2^2 - 4\cdot 2 - 1 \\ k=3 \Rightarrow\ 4\cdot 3^3 = 4^4 - 3^4 - 6\cdot 3^2 - 4\cdot 3 - 1 \\ \vdots \qquad\qquad \vdots \qquad\qquad\qquad \vdots \\ k=n \Rightarrow 4\cdot n^3 = (n+1)^4 - n^4 - 6\cdot n^2 - 4\cdot n - 1 \end{cases}$$

$$4S_n = (n+1)^4 - 1^4 - 6(1^2+2^2+3^2+...+n^2) - 4(1+2+3+...+n) - n$$

